# សាសនសុភាសិត

## ភាគ ១

សម្រាប់សាលាធម្មវិន័យ
ថ្នាក់ត្រី

<u>ចម្លងដោយ:</u>

ផ្ទះលេខ១៣៦អឺ០ វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

ព.ស២៥៤១ គ.ស១៩៩៨

អំណោយរបស់លោក ឈុំ ឈុនសំរ៉ង ដល់គម្រោងខ្មែរ សៀវភៅតំកល់
ក្នុង elibrary of Cambodia កក្កដា 2015

# សាសនសុភាសិត

## ភាគ ១

សម្រាប់សាលាធម្មវិន័យ
ថ្នាក់ត្រី

បោះពុម្ពឡើងវិញចំនួន ៣.០០០ ច្បាប់

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស ២៥៣៨ គ.ស ១៩៩៤

## សេចក្តីបញ្ជាក់
## ចំពោះការបោះពុម្ពឡើងវិញ

សៀវភៅ " សាសនសុភាសិត " សម្រាប់សាលាធម្មវិន័យ ត្រូវបានបោះពុម្ពឡើងវិញ ដោយបានទទួលការឧបត្ថម្ភពីគណៈកម្មាធិការជំនួយសូតូស៊ូជប៉ុន (Japan Sotoshu Relief Committee) និងពីអង្គការ រិស្សូ កូសី-កៃ ( Rissho Kosei-Kai) ។

គោលបំណងនៃការបោះពុម្ពឡើងវិញ គឺសំដៅ :

- ផ្តល់អោយពុទ្ធសាសនិក មានគោលធម៌សម្រាប់ទន្ទេញអោយចាំមាត់ស្ទាត់ជួន,
- រក្សាមតិកវប្បធម៌ អក្សរសាស្រ្ត អោយគង់វង្សឡើងវិញ និងរីកចំរើន,
- ផ្សព្វផ្សាយចំណេះចេះដឹងទូទៅក្នុងពលរដ្ឋកម្ពុជា ។

ពុទ្ធសាសនបណ្ឌិត្យ នឹងចេះតែខិតខំចាត់ការបោះពុម្ព ទាំងសៀវភៅសិក្សា ទាំងសៀវភៅអានគ្រប់បែបយ៉ាង ដែលពុទ្ធសាសនបណ្ឌិត្យពីមុនធ្លាប់មាន ដើម្បីតម្រូវទៅតាមការចាំបាច់ប្រើប្រាស់របស់សាធារណជន ទាំងព្រះសង្ឃ ទាំងគ្រហស្ថផង ដើម្បីរួមចំណែកដល់ការកសាងប្រទេសកម្ពុជា ខាងវិស័យវប្បធម៌ និងអក្សរសាស្រ្តផង ។

សូមឧទ្ទិសសៀវភៅ " សាសនសុភាសិត " នេះ ចំពោះការរីកចំរើនស្មារតីសិក្សា, ស្មារតីស្រឡាញ់ និងលើកស្ទួយអក្សរសាស្រ្តជាតិ ហើយជាពិសេស ស្មារតីបង្រួបបង្រួមជាតិ ដើម្បីសុខសន្តិភាពដ៏ស្ថិតស្ថេរ នៅកម្ពុជា !

សូមជនានុជនក្នុងកម្ពុជរដ្ឋ បានចំរើនល្អលាស់ដុះដាលដោយវិជ្ជា និងវិបុលសុខគ្រប់ប្រការ ហើយរួបរួមគ្នាកសាងប្រទេស និងលើកស្ទួយអក្សរសាស្រ្តជាតិ និងព្រះពុទ្ធសាសនា អោយបានរីកចំរើន ជាភិយ្យោភាព តរៀងទៅ ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះគណៈកម្មាធិការជំនួយស្វេតស៊ុយជប៉ុន និង អង្គការ វិស្សូ ក្លូសិ-កៃ ដែលបានផ្តល់ការឧបត្ថម្ភយ៉ាងឧត្តុង្គឧត្តមដល់ការបោះពុម្ពសៀវភៅនេះ ។

ភ្នំពេញ, ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ១៩៩៤

ពុទ្ធសាសនបណ្ឌិត្យ

## ごあいさつ

この本は、立正佼成会と曹洞宗国際ボランティア会との共同プロジェク
して印刷されました。

この本が、日本の仏教徒とカンボジアの人々との友情のきずなとなり、
ボジアの文化発展に貢献できれば幸いです。


## ACKNOWLEDGEMENT

This book has been printed by Japan Sotoshu Relief Committe (JSRC) with the contribution from

RISSHO KOSEI-KAI

We pray that this book would contribute to the frienship wi Cambodian people and their religious and cultural preservation.

## និវេទនកថា

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយអង្គការជំនួយសូតូស៊ូជប៉ុន (JSRC ដោយមានការឧបត្ថម្ភពី

មូលនិធិអង្គការ រិស្សូ កូសី-កៃ

យើងខ្ញុំអធិដ្ឋាន សូមអោយសៀវភៅនេះ បានជាវិភាគទានរក្សាមិត្តភាពជាមួយប្រជាជ កម្ពុជា និងថែរក្សាសម្បត្តិសាសនា និងសម្បត្តិវប្បធម៌របស់ប្រជាជនកម្ពុជា ។

# អារម្ភកថា

សៀវភៅ សាសនសុភាសិត ភាគ ១ សម្រាប់ធម្មវិន័យថ្នាក់ត្រីនេះ គណៈកម្មការធម្មវិន័យ បានរៀបរៀងឡើងនៅក្រោមព្រះបរមរាជូបត្ថម្ភ ទាំងអស់ដោយការប្រែតាមព្យញ្ជនៈខ្លះ, ប្រែសម្រួលសេចក្ដីតាមអដ្ឋកថាខ្លះ, ប្រែសម្រួលសេចក្ដីតាមភាសាខ្មែរខ្លះ ជាគោលធម៌សម្រាប់សិក្សាតាមកុលបុត្រសិក្សាជាដំបូង ៗ ចែកជា ២ ផ្នែក ជាសៀវភៅដាច់ដោយឡែក ១ គឺ:

១– សេចក្ដីសង្ខេបជាគោលធម៌សម្រាប់ទន្ទេញឲ្យចាំមាត់ស្ទួន ៗ

២– សេចក្ដីអធិប្បាយគោលធម៌ សម្រាប់មើលពិចារណាឲ្យយល់ ៗ

សម្ដេចព្រះមហាសុមេធាធិបតី (ជោតញ្ញាណោ ជ.ណ.) ជាប្រធានគណៈកម្មការ បានផ្ទៀងផ្ទាត់ពិនិត្យឃើញថា សៀវភៅសាសនសុភាសិតសម្រាប់ធម្មវិន័យថ្នាក់ត្រីនេះ ត្រឹមត្រូវគួរដល់ការសិក្សាហើយ សៀវភៅនេះទុកជាគោលច្បាប់ដ៏ប្រសើរ ខាងផ្នែកសិក្សាធម្មវិន័យក្នុងព្រះពុទ្ធសាសនាតទៅ ៗ

គណៈកម្មការមានសមាជិក ២១ រូបគឺ:

១– សម្ដេចព្រះមហាសុមេធាធិបតី (ជោតញ្ញាណោ ជ. ណ.) សង្ឃនាយកគណៈមហានិកាយ (វត្តឧណ្ណាលោម) ជាប្រធាន

២-ព្រះពោធិវង្ស (សុវណ្ណវជិរប្បញ្ញោ ហ. តាត) ចាងហ្វាងសាលាបាលីជាន់ខ្ពស់ (វត្តឧណ្ណាលោម) ជាក្រុមជំនុំ

៣ ព្រះមហាព្រហ្មមុនី (បិតវីរិយោ ខ. អ៊ុ) ចាងហ្វាងរងសាលាបាលីជាន់ខ្ពស់ (វត្តស្វាយពពែ) ជាអនុប្រធានទី ១

៤-ព្រះឧបាលិវង្ស (ចន្ទធម្មោ ម. សែស វត្តមហាមន្ត្រី) ជាអនុប្រធានទី ២

៥-ព្រះអមរាភិរក្ខិត (ខេមកោ អ. ប៉ាង) ក្រុមជំនុំព្រះត្រៃបិដក (វត្តបទុមវត្តី) ជាក្រុមជំនុំ

៦-ព្រះវិឧញ្ញាណ (សិរីបញ្ញោ ក. ស៊ុម) សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ (វត្តលង្កា) ជាក្រុមជំនុំ

៧-ព្រះឥន្ទមុនី (ញាណវីរិយោ ក. ទុយ) (វត្តឧណ្ណាលោម) ជាក្រុមជំនុំ

៨-ព្រះទេពមុនី (ឥន្ទសុវណ្ណោ យ. ប៉ុណ្ណ) ក្រុមជំនុំព្រះត្រៃ-បិដក (វត្តឧណ្ណាលោម) ជាក្រុមជំនុំ

៩-ព្រះទេពសត្ថា (សុវណ្ណសរោ ស. ហាយ) ក្រុមជំនុំព្រះត្រៃ-បិដក (វត្តឧណ្ណាលោម) ជាក្រុមជំនុំ

១០ ព្រះធម្មត្រៃលោកាចារ្យ (បិតសីលោ ក. តោ) សាស្ត្រាចារ្យ

សាលាបាលីជាន់ខ្ពស់ (វត្តបទុមវត្តី) ជាក្រុមជំនុំ

១១–ព្រះធម្មវរោត្តម (ធម្មសិរី ម.សុវណ្ណ) ក្រុមជំនុំព្រះត្រៃបិដក (វត្តស្វាយពពែ) ជាក្រុមជំនុំ

១២–ព្រះញាណវីរិយ (គិរិស្សរោ វ. សាឌុម) ក្រុមជំនុំព្រះត្រៃបិដក (វត្តទួនមណី) ជាក្រុមជំនុំ

១៣–ព្រះធម្មមុនី (កុវិញ្ញាណោ ហ. ហ៊) ក្រុមជំនុំព្រះត្រៃបិដក (វត្តបទុមវត្តី) ជាក្រុមជំនុំ

១៤–ព្រះគ្រូញាណសត្ថា (ញាណសាគរោ ប. សុខ) សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ (វត្តឧណ្ណាលោម) ជាក្រុមជំនុំ

១៥–ព្រះគ្រូពោធិវង្សបរិយត្តិ (សុវណ្ណកេសរោ វ. គឹម) សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ (វត្តសារាវ័ន) ជាក្រុមជំនុំ

១៦–ព្រះគ្រូសិរីសោភ័ណ (ចន្ទមង្គលោ ក. គួរ) ក្រុមជំនុំព្រះត្រៃបិដក (វត្តឧណ្ណាលោម) ជាក្រុមជំនុំ

១៧–ព្រះគ្រូមុនីសោភ័ណ (សារញ្ញាណោ ស. ទាន) សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ (វត្តឧណ្ណាលោម) ជាក្រុមជំនុំ

១៨–ព្រះគ្រូសង្ឃសត្ថា (ធម្មាភាសោ ប៉. សុភ័ដ) សាស្ត្រាចារ្យ

សាលាបាលីជាន់ខ្ពស់ (វត្តឧណ្ណាលោម) ជាក្រុមជំនុំ

១៩–ព្រះគ្រូមហាបទុម (បណ្ឌា ប៉ោ ម-ស៊ុនួ) ក្រុមជំនុំព្រះត្រៃបិដក (វត្តបទុមវត្តី) ជាក្រុមជំនុំ

២០–ព្រះសាសនរង្សី (ធម្មកេសរត្ថេរ គ-ស្រូក) ក្រុមជំនុំព្រះត្រៃបិដក (វត្តសារាវ័ន) ជាក្រុមជំនុំ

២១–ព្រះមហាវិរិយបណ្ឌិតោ (ប៉ី. ទាត់) ក្រុមជំនុំព្រះត្រៃបិដក (វត្តឧណ្ណាលោម) ជាក្រុមជំនុំ ។

សូមឲ្យការសិក្សាធម្មវិន័យប្រកបដោយវឌ្ឍនភាពជានិច្ចនិរន្តរ៍រៀងទៅ

ថ្ងៃ ៦ ៩ ៤ ឆ្នាំខាលទោស័ក ព.ស.២៤៩៣ ត្រូវនឹងថ្ងៃ

ទី១៦ មីនា គ.ស. ១៩៥១

គណៈកម្មការរៀបរៀងធម្មវិន័យ

# មាតិកានុក្រម


| | | ទំព័រ |
|---|---|---|
| ១- | អត្តវគ្គ | ១ |
| ២- | អប្បមាទវគ្គ | ៦ |
| ៣- | កម្មវគ្គ | ៧ |
| ៤- | កិលេសវគ្គ | ១១ |
| ៥- | កោធវគ្គ | ១៥ |
| ៦- | ខន្តិវគ្គ | ២០ |
| ៧- | ចិត្តវគ្គ | ២២ |
| ៨- | ជយវគ្គ | ២៤ |
| ៩- | ទានវគ្គ | ២៦ |
| ១០- | ទុក្ខវគ្គ | ២៩ |
| ១១- | ធម្មវគ្គ | ៣០ |
| ១២- | បកិណ្ណកវគ្គ | ៣៤ |
| ១៣- | បញ្ញាវគ្គ | ៤៣ |
| ១៤- | បមាទវគ្គ | ៤៧ |
| ១៥- | បាបវគ្គ | ៤៩ |
| ១៦- | បុគ្គលវគ្គ | ៥២ |

ទំព័រ


| | | |
|---|---|---|
| ១៧- | បុញ្ញវគ្គ | ៦៤ |
| ១៨- | មច្ចុវគ្គ | ៦៥ |
| ១៩- | មិត្តវគ្គ | ៦៧ |
| ២០- | យាចនាវគ្គ | ៧០ |
| ២១- | ភជវគ្គ | ៧១ |
| ២២- | ក៏ចាវគ្គ | ៧២ |
| ២៣- | វីរិយវគ្គ | ៧៥ |
| ២៤- | វេរវគ្គ | ៧៧ |
| ២៥- | សប្បវគ្គ | ៧៨ |
| ២៦- | សតិវគ្គ | ៧៩ |
| ២៧- | សត្ថាវគ្គ | ៨០ |
| ២៨- | សទ្ធម្មវគ្គ | ៨១ |
| ២៩- | សមណវគ្គ | ៨២ |
| ៣០- | សាមគ្គីវគ្គ | ៨៤ |
| ៣១- | សីលវគ្គ | ៨៤ |
| ៣២- | សុខវគ្គ | ៨៦ |
| ៣៣- | សេនាវគ្គ | ៨៨ |

# អក្សរសង្ខេប

## ប្រាប់ឈ្មោះគម្ពីរក្នុងសៀវភៅសាសនសុភាសិតនេះ

| | | | | |
|---|---|---|---|---|
| អង្គ. | អដ្ឋក. | អង្គុត្តរនិកាយ | | អដ្ឋកនិបាត |
| អង្គ. | ចតុក្ក. | — | | ចតុក្កនិបាត |
| អង្គ. | ឆក្ក. | — | | ឆក្កនិបាត |
| អង្គ. | តិក. | — | | តិកនិបាត |
| អង្គ. | ទសក. | — | | ទសកនិបាត |
| អង្គ. | បញ្ចក. | — | | បញ្ចកនិបាត |
| អង្គ. | សត្តក. | — | | សត្តកនិបាត |
| ខុ. | ឥតិ | ខុទ្ទកនិកាយ | | ឥតិវុត្តកៈ |
| ខុ. | ឧ. | — | | ឧទាន |
| ខុ. | ខុ. | — | | ខុទ្ទកបាឋ |
| ខុ. | ចរិយា. | — | | ចរិយាបិដក |
| ខុ. | ចូ. | — | | ចូឡនិទ្ទេស |
| ខុ. | ជា អដ្ឋក. | — | ជាតក | អដ្ឋកនិបាត |
| ខុ. | ជា. អសីតិ. | — | — | អសីតិនិបាត |
| ខុ. | ជា. ឯក. | — | | ឯកនិបាត |

| | | | | | |
|---|---|---|---|---|---|
| ខុ. | ជា. | ចត្តាឡីស. | ខុទ្ទកនិកាយ | ជាតក | ចត្តាឡីសនិបាត |
| ខុ. | ជា. | ចតុក្ក. | — | — | ចតុក្កនិបាត |
| ខុ. | ជា. | ឆក្ក. | — | — | ឆក្កនិបាត |
| ខុ. | ជា. | តឹស. | — | — | តឹសនិបាត |
| ខុ. | ជា. | តិក. | — | — | តិកនិបាត |
| ខុ. | ជា. | តេរស. | — | — | តេរសនិបាត |
| ខុ. | ជា. | ទ្វាទស. | — | — | ទ្វាទសនិបាត |
| ខុ. | ជា. | ទសក. | — | — | ទសកនិបាត |
| ខុ. | ជា. | ទុក. | — | — | ទុកនិបាត |
| ខុ. | ជា. | នវក. | — | — | នវកនិបាត |
| ខុ. | ជា. | បកិណ្ណក. | — | — | បកិណ្ណកវគ្គ |
| ខុ. | ជា. | បញ្ចក. | — | — | បញ្ចកវគ្គ |
| ខុ. | ជា. | បញ្ញាស. | — | — | បញ្ញាសវគ្គ |
| ខុ. | ជា. | មហា. | — | — | មហានិបាត |
| ខុ. | ជា. | វីស. | — | — | វីសតិនិបាត |
| ខុ. | ជា. | សដ្ឋី. | — | — | សដ្ឋីនិបាត |
| ខុ. | ជា. | សត្តក. | — | — | សត្តកនិបាត |

= ពិ =

| | | | | | |
|---|---|---|---|---|---|
| ខុ. | ជា. | សត្តតិ. | ខុទ្ទកនិកាយ | ជាតក | សត្តតិនិបាត |
| ខុ. | | ថេរ. | — | | ថេរគាថា |
| ខុ. | | ថេរី. | — | | ថេរីគាថា |
| ខុ. | | ធ. | — | | ធម្មបទគាថា |
| ខុ. | | បដិ. | — | | បដិសម្ភិទាមគ្គ |
| ខុ. | | ពុ. | — | | ពុទ្ធវំស |
| ខុ. | | មហា. | — | | មហានិទ្ទេស |
| ខុ. | | សុ. | — | | សុត្តនិបាត |
| វិ. | | ចុល. | វិនយបិដក | | ចុល្លវគ្គ |
| ទី. | | បាដិ. | ទីឃនិកាយ | | បាដិកវគ្គ |
| ទី. | | មហា. | — | | មហាវគ្គ |
| វិ. | | ភិ. | វិនយបិដក | | ភិក្ខុនីវិភង្គ |
| ម. | | ឧប. | មជ្ឈិមនិកាយ | | ឧបរិបណ្ណាសក |
| ម. | | ម. | — | | មជ្ឈិមបណ្ណាសក |

| | | | |
|---|---|---|---|
| វិ. | មហា. | វិនយបិដក | មហាវគ្គ |
| សំ. | និ. | សំយុត្តនិកាយ | និទានវគ្គ |
| សំ. | មហា. | – | មហាវារវគ្គ |
| សំ. | ស. | – | សគាថវគ្គ |
| សំ. | សឡា. | – | សឡាយតនវគ្គ |
| វិ. | មហាវិភង្គ | វិនយបិដក | មហាវិភង្គ |
| កា. | កា. | កាសិតោវាទ | កាណវៈ |

# សាសនសុភាសិត

## ១ - អត្តវគ្គ

"ពួកធម៌និយាយអំពីខ្លួន"

១- អត្តា ហវេ ជិតំ សេយ្យោ

ឈ្នះខ្លួនឯង ប្រសើរជាង

ខុ. ធ.

២- អត្តា ហិ កិរ ទុទ្ទមោ

លោកថាខ្លួនហ្នឹងហើយ ដែលបុគ្គលទូន្មានបានដោយកម្រ

ខុ. ធ.

៣- អត្តា សុទន្តោ បុរិសស្ស ជោតិ

ខ្លួនដែលទូន្មានល្អហើយ ជាពន្លឺរបស់បុរស

សំ. ស.

៤- អត្តា ហិ អត្តនោ នាថោ

ខ្លួនជាទីពឹងរបស់ខ្លួនឯង

ខុ. ធ.

៥- អត្តា ហិ អត្តនោ គតិ

ខ្លួនជាគតិរបស់ខ្លួនឯង

ខុ. ធ.

៦- អត្តា ហិ បរមំ បិយោ

ខ្លួនឯងជាទីស្រឡាញ់ក្រៃលែង

អង្គ. សត្តក.

៧- នត្ថិ អត្តសមំ បេមំ

សេចក្ដីស្រឡាញ់អ្វីស្មើនឹងខ្លួនមិនមានឡើយ

សំ. ស.

៨- អត្តនា វ កតំ បាបំ អត្តនា សង្កិលិស្សតិ

ធ្វើបាបដោយខ្លួនឯង រមែងសៅហ្មងដោយខ្លួនឯង

ខុ. ធ., ខុ. មហា., ខុ. ចូ.

៩- អត្តនា អកតំ បាបំ អត្តនា វ វិសុជ្ឈតិ

មិនធ្វើបាបដោយខ្លួនឯង រមែងបរិសុទ្ធដោយខ្លួនឯង

ខុ. ធ., ខុ. មហា., ខុ. ចូ.

១០- អត្តត្ថបញ្ញា អសុចី មនុស្សា

ពួកអ្នកឃើញតែប្រយោជន៍ខ្លួន ហៅថាមនុស្សអសោចិ៍

ខុ. សុ.

១១- អត្តានំ ទមយន្តិ បណ្ឌិតា

បណ្ឌិតទាំងឡាយរមែងទូន្មានខ្លួន

ខុ. ធ., ម. ម., ខុ. ថេរ.

១២– អត្តានំ ទមយន្តិ សុព្វតា

អ្នកប្រព្រឹត្តល្អ រមែងទូន្មានខ្លួនបាន

ខុ. ធ.

១៣– អត្តនា ហិ សុទន្តេន នាថំ លភតិ ទុល្លភំ

បុគ្គលមានខ្លួនទូន្មានល្អហើយ រមែងបានទីពឹងដែលគេបានដោយកម្រ

ខុ. ធ.

១៤ យោ ច រក្ខតិ អត្តានំ រក្ខិតោ តស្ស ពាហិរោ

អ្នកណារក្សាខ្លួនបានខាងក្រៅរបស់អ្នកនោះ ឈ្មោះថាខ្លួនបានរក្សាហើយ

អង្គ. ឆក្ក.

១៥ អត្តានញ្ចេ បិយំ ជញ្ញា រក្ខេយ្យ នំ សុរក្ខិតំ

បើដឹងថាខ្លួនជាទីស្រឡាញ់ ក៏ត្រូវរក្សាខ្លួននោះឲ្យល្អ

ខុ. ធ.

១៦–បរិយោទបេយ្យ អត្តានំ ចិត្តក្លេសេហិ បណ្ឌិតោ

បណ្ឌិតគប្បីធ្វើខ្លួនឲ្យផូរផង់ចាកគ្រឿងសៅហ្មងចិត្តទាំងឡាយ

ខុ. ធ., សំ. មហា.

១៧– អត្តានញ្ចេ តថា កយិរា យថញ្ញមនុសាសតិ

បើប្រៀនប្រដៅអ្នកដទៃយ៉ាងណា ក៏ត្រូវធ្វើខ្លួនយ៉ាងនោះដែរ

ខុ. ធ.

១៨– អត្តនា ចោទយត្តានំ

ចូរចោទខ្លួនដោយខ្លួនឯង

ខុ. ធ.

១៩– បដិមំសេ តមត្តនា

ចូរពិចារណាខ្លួនដោយខ្លួនឯង

ខុ. ធ.

២០– ទុគ្គា ឧទ្ធរថត្តានំ បង្កេ សន្នោវ កុញ្ជរោ

ចូរលើកខ្លួនឡើងចាកភក់ ដូចដំរីជាប់ភក់ហើយលើកខ្លួនឡើងបាន

ខុ. ធ.

២១– អត្តានុរក្ខី ភវ មា អឌយ្ហិ

ចូរអ្នករក្សាខ្លួនហើយ ៗ កុំដុតខ្លួនឡើយ

ខុ. ជា. បកិណ្ណក.

២២– អត្តានញ្ច ន ឃាតេសិ

កុំសម្លាប់ខ្លួនឯងឡើយ

ខុ. ជា. មហា.

២៣– អត្តានំ ន ទទេ បោសោ

បុរសមិនត្រូវឲ្យខ្លួន

សំ. ស.

២៤- អត្តានំ ន បរិច្ចជេ

បុរសមិនគប្បីលះបង់នូវខ្លួន

សំ. ស.

២៥- អត្តានំ នាតិវត្តេយ្យ

បុគ្គលមិនគួរប្រព្រឹត្តហួសខ្លួន

ខុ. ជា. តឹស.

២៦- អត្តទត្ថំ បរត្ថេន ពហុនាបិ ន ហាបយេ

មិនគួរធ្វើប្រយោជន៍ខ្លួនឲ្យសាបសូន្យដោយច្រើន

ព្រោះតែប្រយោជន៍អ្នកដទៃឡើយ

ខុ. ធ.

២៧- អត្តានញ្ចេ បិយំ ជញ្ញា ននំ បាបេន សំយុជេ

បើដឹងថាខ្លួនជាទីស្រឡាញ់ មិនគួរប្រកបខ្លួននោះ

ដោយអំពើអាក្រក់ឡើយ

សំ. ស.

២៨- យទត្តគរហី តទកុព្វមានោ

តិះដៀលខ្លួនឯងដោយហេតុណា មិនគួរធ្វើហេតុនោះឡើយ

ខុ. សុ.

---

## ២- អប្បមាទវគ្គ

“ពួកគាថានិយាយអំពីសេចក្ដីមិនប្រមាទ”

២៩- អប្បមាទោ អមតំ បទំ

សេចក្ដីមិនប្រមាទ ជាផ្លូវមិនស្លាប់

ខុ. ធ., ខុ. ជា. តឹស.

៣០- អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំវ រក្ខតិ

អ្នកប្រាជ្ញតែងរក្សាសេចក្ដីមិនប្រមាទ ដូចគេរក្សាទ្រព្យដ៏ប្រសើរបំផុត

ខុ. ធ., ម. ម., សំ. ស., ខុ. ថេរ.

៣១- អប្បមាទំ បសំសន្តិ

បណ្ឌិតទាំងឡាយតែងសរសើរសេចក្ដីមិនប្រមាទ

ខុ. ធ., ស. ស., អង្គ. បញ្ចក., ខុ. ឥតិ.

៣២- អប្បមាទេ បមោទន្តិ

បណ្ឌិតទាំងឡាយ តែងត្រេកអរក្នុងសេចក្ដីមិនប្រមាទ

ខុ. ធ.

៣៣- អប្បមត្តា ន មីយន្តិ

អ្នកមិនប្រមាទ ឈ្មោះថាមិនស្លាប់

ខុ. ធ., ខុ. ជា. តឹស.

៣៤- អប្បមត្តោ ហិ ឈាយន្តោ បប្បោតិ វិបុលំ សុខំ

*អ្នកមិនប្រមាទចេះសង្កេតពិនិត្យ តែងដល់នូវសុខដ៏ទូលាយ*

ខុ. ធ., ម. ម., សំ. ស., ខុ. ថេរ.

៣៥- អប្បមត្តោ ឧភោ អត្ថេ អធិគ្គណ្ហាតិ បណ្ឌិតោ

*បណ្ឌិតអ្នកមិនប្រមាទ រមែងបានទទួលប្រយោជន៍ទាំងពីរ*

សំ. ស., អង្គ. បញ្ចក., ខុ. ឥតិ.

៣៦- អប្បមាទេន សម្បាទេថ

*អ្នកទាំងឡាយ ចូរញុំាងសេចក្តីមិនប្រមាទឲ្យដល់ព្រម*

ទី. មហា., សំ. ស.

៣៧- អប្បមាទរតា ហោថ

*អ្នកទាំងឡាយ ចូរជាអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ*

ខុ. ធ.

---

## ៣- កម្មវគ្គ

" ពួកធម៌និយាយអំពីកម្ម (អំពើ) "

៣៨- កម្មំ សត្តេ វិភជតិ យទិទំ ហីនប្បណីតតាយ

*កម្មតែងចែកសត្វទាំងឡាយ ឲ្យថោកទាបនិងថ្លៃថ្លា*

ម. ឧ.

៣៩- យំ កិញ្ចិ សិថិលំ កម្ម ន តំ ហោតិ មហប្ផលំ

កម្មណាមួយធូរថយ កម្មនោះមិនមានផលច្រើនឡើយ

សំ. ស.

៤០- សានិ កម្មានិ នយន្តិ ទុគ្គតឹ

អកុសលកម្មទាំងឡាយរបស់ខ្លួន តែងនាំទៅកាន់ទុគ្គតិ

ខុ. ធ.

៤១- សុករំ សាធុនា សាធុ

កម្មល្អមនុស្សល្អធ្វើបានដោយងាយ

វិ. ចុល., ខុ. ឧ.

៤២- សាធុ បាបេន ទុក្ករំ

កម្មល្អមនុស្សអាក្រក់ធ្វើបានដោយកម្រ

វិ. ចុល., ខុ. ឧ.

៤៣- អកតំ ទុក្កដំ សេយ្យោ

អំពើអាក្រក់ដែលគេមិនធ្វើ ល្អជាង

ខុ. ធ., សំ. ស.

៤៤- បច្ឆា តបតិ ទុក្កដំ

កម្មអាក្រក់តែងដុតកំដៅក្នុងកាលជាខាងក្រោយ

សំ. ស., ខុ. ធ.

៤៥- កតញ្ច សុកតំ សេយ្យោ

អំពើល្អដែលគេធ្វើហើយ ឈ្មោះថាល្អជាង

ខុ. ធ., សំ. ស.

៤៦- ន តំ កម្មំ កតំ សាធុ យំ កត្វា អនុតប្បតិ

គេធ្វើកម្មណាហើយក្ដៅកេលកល ខាងក្រោយ

កម្មដែលគេធ្វើហើយនោះមិនល្អទេ

សំ. ស., ខុ. ធ.

៤៧- តញ្ច កម្មំ កតំ សាធុ យំ កត្វា នានុតប្បតិ

គេធ្វើកម្មណាហើយមិនក្ដៅកេលកលខាងក្រោយ

កម្មដែលគេធ្វើហើយនោះឯងជាកម្មល្អ

សំ. ស., ខុ. ធ.

៤៨- សុករានិ អសាធូនិ អត្តនោ អហិតានិ ច

កម្មមិនល្អ ទាំងកម្មមិនជាប្រយោជន៍ដល់ខ្លួន មនុស្សអាក្រក់ធ្វើបានងាយ

ខុ. ធ.

៤៩- យំ វេ ហិតញ្ច សាធុញ្ច តំ វេ បរមទុក្ករំ

កម្មណាជាប្រយោជន៍ផង ល្អផង កម្មនោះឯង

គេធ្វើបានដោយលំបាកក្រៃពេក

ខុ. ធ.

៥០- ន ហិ តំ សុលភំ ហោតិ សុខំ ទុក្កដការិនា

*អ្នកធ្វើអាក្រក់ហើយ មិនងាយនឹងបានសេចក្ដីសុខនោះឡើយ*

សំ. ស.

៥១- កល្យាណការី កល្យាណំ បាបការី ប បាបកំ

*អ្នកធ្វើកម្មល្អ បានល្អ អ្នកធ្វើកម្មអាក្រក់ បានអាក្រក់*

សំ. ស., ខុ. ជា. ទុក.

៥២- កម្មុនា វត្តតី លោកោ

*សត្វលោកតែងប្រព្រឹត្តទៅតាមកម្ម*

ម. ម., ខុ. សុ.

៥៣- បដិកច្ចេវ តំ កយិរា យំ ជញ្ញា ហិតមត្តនោ

*ដឹងថាកម្មណាជាប្រយោជន៍ដល់ខ្លួន គួរប្រញាប់ប្រញាល់*

*ធ្វើនូវកម្មនោះឲ្យបានមុនគេ*

សំ. ស.

៥៤ កយិរា ចេ កយិរាថេនំ

*បើធ្វើការអ្វីត្រូវធ្វើការនោះ ( ឲ្យពិតៗ )*

សំ. ស., ខុ. ធ.

៥៥- ករេយ្យ វាក្យំ អនុកម្បកានំ

គួរធ្វើតាមពាក្យរបស់អ្នកអនុគ្រោះទាំងឡាយ

ខុ.ជា. ទសក.

៥៦- កិច្ចានុកុព្វស្ស ករេយ្យ កិច្ចំ

គប្បីធ្វើកិច្ចដល់អ្នកជួយធ្វើកិច្ច

ខុ.ជា. ទសក.

៥៧- នានត្ថកាមស្ស ករេយ្យ អត្ថំ

មិនគួរធ្វើប្រយោជន៍ ដល់អ្នកប្រាថ្នាសេចក្ដីវិនាសឡើយ

ខុ.ជា. ទសក.

---

## ៤- កិលេសវគ្គ

" ពួកធម៌និយាយអំពីកិលេស ( គ្រឿងសៅហ្មងចិត្ត ) "

៥៨- សង្កប្បរាគោ បុរិសស្ស កាមោ

រាគៈដែលកើតឡើងព្រោះតម្រិះ ជាកាមរបស់បុរស

សំ.ស. , អង្គ. ឆក្ក.

៥៩- ន សន្តិ កាមា មនុជេសុ និច្ចា

កាមទាំងឡាយដ៏ទៀងទាត់ ក្នុងពួកមនុស្សមិនមានឡើយ

សំ.ស.

៦០– កាមេហិ លោកម្ហិ ន ហត្ថិ តិត្តិ

*សេចក្ដីឆ្អែតដោយកាមទាំងឡាយមិនមានក្នុងលោកឡើយ*

ម.ម., ខុ. ថេរ.

៦១– ន កហាបណវស្សេន តិត្តិ កាមេសុ វិជ្ជតិ

*សេចក្ដីឆ្អែតក្នុងកាមទាំងឡាយ ដោយភ្លៀងគឺកហាបណៈមិនមានឡើយ*

ខុ. ធ., ខុ. ជា. តិក.

៦២– នត្ថិ កាមា បរំ ទុក្ខំ

*ទុក្ខក្រៅពីកាមមិនមាន*

ខុ. ជា. ឯកាទសក.

៦៣– នត្ថិ តណ្ហាសមា នទី

*នទីស្មើដោយតណ្ហាមិនមាន*

ខុ. ធ.

៦៤– តណ្ហា លោកស្មិំ ទុជ្ជហា

*តណ្ហា គេលះបង់បានដោយក្រក្នុងលោក*

សំ. ស.

៦៥- តណ្ហា ហិ អនន្តគោចរា

មែនពិត តណ្ហា មានគោចរគេរាប់ផុតគ្មាន

ខុ. ជា. ទុក.

៦៦- តណ្ហា នរំ បរិកស្សតិ

តណ្ហា តែងទាញកន្ត្រាក់នូវនរជន

សំ. ស.

៦៧- នត្ថិ រាគសមោ អគ្គិ

ភ្លើងស្មើដោយរាគៈមិនមាន

ខុ. ធ.

៦៨- លោភោ ធម្មានំ បរិបន្ថោ

សេចក្តីលោភជាអន្តរាយដល់កុសលធម៌ទាំងឡាយ

សំ. ស.

៦៩- អតិលោភោ ហិ បាបកោ

សេចក្តីលោភលន់ជាបាបពិត

វិ. ភិ. , ខុ. ជា. ឯក.

៧០- នត្ថិ មោហសមំ ជាលំ

បណ្តាញស្មើដោយមោហៈមិនមាន

ខុ. ធ.

៣១- ភិយ្យោ ច កាមេ អភិបត្ថយន្តិ

*អ្នកបរិភោគកាម រឹងរឹតតែប្រាថ្នានូវកាមទាំងឡាយ*

ម. ម., ខុ. ជា.

៣២- ឱនា វ ហុត្វាន ជហន្តិ ទេហំ

*អ្នកបរិភោគកាមសុទ្ធតែជាអ្នកខ្វះខាតរៀងរហូតដល់លះបង់កងកាយទៅ*

ម. ម., ខុ. ជា.

៣៣. ភោគតណ្ហាយ ទុម្មេធោ ហន្តិ អញ្ញេវ អត្តនំ

*ព្រោះចំណង់ក្នុងភោគៈ ទើបមនុស្សល្ងង់ សម្លាប់ខ្លួនឯង*

*ដូចសម្លាប់អ្នកដទៃ*

ខុ. ធ.

៣៤ – អវិជ្ជានិវុតា បោសា

*សត្វទាំងឡាយសុទ្ធតែត្រូវអវិជ្ជាបិទបាំង*

វិ. ចុល., អដ្ឋ. ចតុក.

---

## ៥ - កោធវគ្គ

" ពួកធម៌និយាយអំពីសេចក្ដីក្រោធ "

៣៥- ន ហិ សាធុ កោធោ

សេចក្ដីក្រោធមិនល្អសោះឡើយ

ខុ. ជា. ឆក្ក.

៣៦- កោធោ សត្ថមលំ លោកេ

សេចក្ដីក្រោធ ទុកដូចជាច្រែះសស្ត្រាក្នុងលោក

សំ. ស.

៣៧- អនត្ថជននោ កោធោ

សេចក្ដីក្រោធ បង្កនូវសេចក្ដីវិនាស

អង្គ. សត្តក.

៣៨- កោធោ ចិត្តប្បកោបនោ

សេចក្ដីក្រោធ ធ្វើចិត្តឲ្យកំរើក

អង្គ. សត្តក.

៣៩- អន្ធតមំ តទា ហោតិ យំ កោធោ សហតេ នរំ

សេចក្ដីក្រោធគ្របសង្កត់នរជនក្នុងកាលណា

ងងឹតខ្វាក់ក៏រមែងមានក្នុងកាលនោះ

អង្គ. សត្តក., ខុ. មហា.

៨០- អប្បោ ហុត្វា ពហុ ហោតិ វឌ្ឍតេ សោ អខន្តិជោ

*សេចក្តីក្រោធនោះ កើតព្រោះសេចក្តីមិនអត់ធន់ តែងចំរើនឡើង ទោះបីតិចក៏ទៅជាច្រើនបាន*

ខុ. ជា. ទសក.

៨១- កោធោ ទុម្មេធគោចរោ

*សេចក្តីក្រោធ ជាគោចររបស់មនុស្សល្ងង់*

ខុ. ជា. ទសក.

៨២- ទោសោ កោធសមុដ្ឋានោ

*ទោសៈមានសេចក្តីក្រោធជាសមុដ្ឋាន ( ទីកើត )*

ខុ. ជា. ទសក.

៨៣- នត្ថិ ទោសសមោ គហោ

*ការចាប់ស្មើដោយទោសៈមិនមាន*

ខុ. ធ.

៨៤- នត្ថិ ទោសសមោ កលិ

*កំហុសស្មើដោយទោសៈមិនមាន*

ខុ. ធ.

៨៥- កោធំ ឃត្វា សុខំ សេតិ

*សម្លាប់សេចក្តីក្រោធបាន តែងនៅជាសុខ*

សំ. ស.

៨៦- កោធំ ឃត្វា ន សោចតិ

សម្លាប់សេចក្ដីក្រោធបាន មិនសោកឡើយ

សំ. ស.

៨៧- កោធាភិភូតោ កុសលំ ជហាតិ

បុគ្គលត្រូវសេចក្ដីក្រោធគ្របសង្កត់ តែងលះបង់នូវកុសល

ខុ. ជា. ទសក.

៨៨- កោធនោ ទុព្វណ្ណោ ហោតិ

អ្នកក្រោធជាអ្នកមានសម្បុរអាក្រក់

អង្គ. សត្តក.

៨៩- ទុក្ខំ សយតិ កោធនោ

មនុស្សក្រោធតែងនៅជាទុក្ខ

អង្គ. សត្តក.

៩០- អថោ អត្ថំ គហេត្វាន អនត្ថំ បដិបជ្ជតិ

មនុស្សក្រោធកាន់យកប្រយោជន៍ហើយ ប្រតិបត្តិការមិនជាប្រយោជន៍ទៅវិញ

អង្គ. សត្តក

៩១– កោធាភិភូតោ បុរិសោ ធនជានិំ និគច្ឆតិ

បុរសត្រូវសេចក្ដីក្រោធគ្របសង្កត់ តែងដល់នូវសេចក្ដីវិនាសទ្រព្យ

អង្គ. សត្តក.

៩២– កោធសម្មទសម្មត្តោ អាយសក្យំ និគច្ឆតិ

អ្នកស្រវឹងស៊ប់ដោយសេចក្ដីក្រោធ តែងដល់នូវភាពជាអ្នកឥតយសស័ក្ដិ

អង្គ. សត្តក.

៩៣– ញាតិមិត្តា សុហជ្ជាច បរិវជ្ជន្តិ កោធនំ

ញាតិមិត្រនិងសំឡាញ់ទាំងឡាយ តែងវៀរចាកនូវបុគ្គលមានក្រោធ

អង្គ. សត្តក.

៩៤– កុទ្ធោ អត្ថំ ន ជានាតិ

អ្នកក្រោធ តែងមិនដឹងនូវអត្ថ

អង្គ. សត្តក.

៩៥– កុទ្ធោ ធម្មំ ន បស្សតិ

អ្នកក្រោធ រមែងមិនឃើញនូវធម៌

អង្គ. សត្តក.

៩៦– យំ កុទ្ធោ ឧបរោធេតិ សុករំ វិយ ទុក្ករំ

បុគ្គលក្រោធបំផ្លាញនូវរបស់ណាដែលគេលំបាកធ្វើ របស់

ដែលគេលំបាកធ្វើនោះហាក់ដូចជាងាយធ្វើ

អង្គ. សត្តក.

៩៧- បដ្ឋា សោ វិគតេ កោធេ អគ្គិទឌ្ឍោវ តប្បតិ

ខាងក្រោយ កាលសេចក្ដីក្រោធរលត់បាត់ហើយ អ្នកក្រោធនោះ

រមែងក្ដៅក្រហាយ ដូចត្រូវភ្លើងឆេះ

អង្គ. សត្តក.

៩៨- កោធេន អភិភូតស្ស ន ទីបំ ហោតិ កិញ្ចនំ

បុគ្គលត្រូវសេចក្ដីក្រោធគ្របសង្កត់ហើយ ឥតមាន

ទីពឹងតិចតួចឡើយ

អង្គ. សត្តក.

៩៩- ហន្តិ កុទ្ធោ សមាតរំ

អ្នកក្រោធតែងសម្លាប់មាតារបស់ខ្លួនបាន ( ហ៊ានសម្លាប់

ម្ដាយរបស់ខ្លួនបានឥតញញើត )

អង្គ. សត្តក.

១០០- កោធជាតោ បរាភវោ

អ្នកមានសេចក្ដីក្រោធកើតហើយ ជាអ្នកវិនាស

អង្គ. សត្តក.

១០១- កោធំ ទមេន ឧច្ឆិន្ទេ

បុគ្គលគប្បីកាត់នូវសេចក្ដីក្រោធ ដោយការទូន្មានចិត្ត

អង្គ. សត្តក.

១០២- កោធំ បញ្ញាយ ឧច្ឆិន្ទេ

*បុគ្គលគប្បីកាត់នូវសេចក្តីក្រោធ ដោយបញ្ញា*

អង្គ. សត្ត.

១០៣- មា កោធស្ស វសំ គមិ

*កុំលុះអំណាចនៃសេចក្តីក្រោធឡើយ*

ខុ. ជា. ទសក

---

## ៦- ខន្តិវគ្គ

" ពួកធម៌និយាយអំពីខន្តី ( អំណត់ ឬសេចក្តីអត់ធន់ ) "

១០៤- ខន្តី បរមំ តបោ តិតិក្ខា

*ខន្តី គឺអំណត់ ជាតបៈ ដ៏ក្រៃលែង*

ទី. មហា., ខុ. ធ.

១០៥- ខន្តិ ហិតសុខាវហា

*សេចក្តីអត់ធន់ ជាគុណជាតិនាំមកនូវប្រយោជន៍នឹងសេចក្តីសុខ*

ក. ក.

១០៦- ខន្តី ធីរស្សលង្ការោ

*សេចក្តីអត់ធន់ជាគ្រឿងប្រដាប់របស់អ្នកប្រាជ្ញ*

ក. ក.

១០៧– ខន្តិ តបោ តបស្សិនោ

*សេចក្ដីអត់ធន់ ជាតបៈរបស់អ្នកមានព្យាយាម*

ក. ក.

១០៨– ខន្តិ ពលំ វ យតីនំ

*សេចក្ដីអត់ធន់ ជាកម្លាំងរបស់អ្នកប្រព្រឹត្តធម៌ទាំងឡាយ*

ក. ក.

១០៩- ខន្តិពលា សមណាព្រាហ្មណា

*សមណព្រាហ្មណ៍ទាំងឡាយ មានសេចក្ដីអត់ធន់ជាកម្លាំង*

អង្គ. អដ្ឋក.

១១០– បិយោ ទេវមនុស្សានំ មនាបោ ហោតិ ខន្តិកោ

*អ្នកមានសេចក្ដីអត់ធន់ជាទីស្រឡាញ់ពេញចិត្តនៃទេវតានិង*

*មនុស្សទាំងឡាយ*

ក. ក.

## ៣- ចិត្តវគ្គ

"ពួកធម៌និយាយអំពីចិត្ត"

១១១- ចិត្តេ សង្កិលិដ្ឋេ ទុគ្គតិ បាដិកង្ខា

កាលបើចិត្តសៅហ្មងហើយ ទុគ្គតិក៏កើតប្រាកដ (បើទុកជាមិនចង់បាន ក៏គង់តែនឹងបានពុំខាន)

ម. ម.

១១២- ចិត្តេ អសង្កិលិដ្ឋេ សុគតិ បាដិកង្ខា

កាលបើចិត្តមិនសៅហ្មងហើយ សុគតិក៏កើតប្រាកដ (បើទុកជាមិនចង់បាន ក៏គង់តែនឹងបានពុំខាន)

ម. ម.

១១៣- ចិត្តេន នីយតិ លោកោ

សត្វលោកដែលត្រូវតែចិត្តដឹកនាំទៅ

សំ. ស.

១១៤- ចិត្តស្ស ទមថោ សាធុ

ការទូន្មានចិត្ត ជាការប្រពៃ

ខុ. ធ.

១១៥- ចិត្តំ ទន្តំ សុខាវហំ

ចិត្តដែលគេទូន្មានបានហើយនាំសុខមកឲ្យ

ខុ. ធ.

១១៦- ចិត្តំ គុត្តំ សុខាវហំ

ចិត្តដែលគេគ្រប់គ្រងហើយនាំសុខមកឲ្យ

ខុ.ធ.

១១៧- វិហញ្ញតិ ចិត្តវសានុវត្តី

អ្នកប្រព្រឹត្តតាមអំណាចចិត្តរមែងលំបាក

ខុ. ជា. ទុក.

១១៨- ចិត្តំ អត្តនោ ឧជុកមកំសុ

បណ្ឌិតទាំងឡាយ បានធ្វើចិត្តរបស់ខ្លួនឲ្យត្រង់ហើយ

ទី. មហា.

១១៩- សចិត្តបរិយាយកុសលា ភវេយ្យុំ

បុគ្គលទាំងឡាយគប្បីជាអ្នកឈ្លាសក្នុងបរិយាយនៃចិត្តរបស់ខ្លួន

អង្គ. ទសក.

១២០- តេលបត្តំ យថា បរិហរេយ្យ ឯវំ សចិត្តមនុរក្ខេ

បុគ្គលគប្បីរក្សាចិត្តរបស់ខ្លួន ដូចជាគេរក្សាភាជន៍ដែលពេញ

ដោយប្រេង

ខុ. ជា. ឯក.

១២១- សចិត្តមនុរក្ខថ

*អ្នកទាំងឡាយចូររក្សាចិត្តរបស់ខ្លួន*

ខុ. ធ.

១២២- ចិត្តំ រក្ខេថ មេធាវី

*អ្នកមានប្រាជ្ញា គប្បីរក្សានូវចិត្ត*

ខុ. ធ.

១២៣-យតោ យតោ ច បាបកំ តតោ តតោ មនោ និវារយេ

*បើបាបកើតអំពីអារម្មណ៍ណា ៗ បុគ្គលគប្បីហាមចិត្ត*
*ចាកអារម្មណ៍នោះ ៗ*

សំ. ស.

---

## ៨–ជយវគ្គ

"ពួកធម៌និយាយអំពីជំនះ"

១២៤- ជយំ វេរំ បសវតិ

*អ្នកឈ្នះរមែងជួបប្រទះនូវពៀរ*

សំ. ស., ខុ. ធ.

១២៥- សព្វទានំ ធម្មទានំ ជិនាតិ

ធម្មទានរមែងឈ្នះនូវទានទាំងពួង

ខុ.ធ.

១២៦- សព្វរសំ ធម្មរសោ ជិនាតិ

រសធម៌រមែងឈ្នះនូវរសទាំងអស់

ខុ.ធ.

១២៧- សព្វរតិំ ធម្មរតិ ជិនាតិ

សេចក្ដីត្រេកអរក្នុងធម៌ រមែងឈ្នះអំណរទាំងអស់

ខុ.ធ.

១២៨- តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ

ការអស់តណ្ហា រមែងឈ្នះនូវទុក្ខទាំងពួង

ខុ. ធ.

១២៩- ន តំ ជិតំ សាធុ ជិតំ យំ ជិតំ អវជិយ្យតិ

ជំនះណាត្រឡប់ចាញ់វិញ ជំនះនោះជាជំនះមិនល្អឡើយ

ខុ.ជា.ឯក.

១៣០- តំ ខោ ជិតំ សាធុ ជិតំ យំ ជិតំ នាវជិយ្យតិ

ជំនះណាមិនត្រឡប់ចាញ់វិញ ជំនះនោះឯងជាជំនះល្អ

ខុ. ជា. ឯក.

១៣១- អក្កោធេន ជិនេ កោធំ

*បុគ្គលគប្បីឈ្នះនូវមនុស្សក្រោធ ដោយការមិនក្រោធ*

ខុ.ធ., ខុ.ជា. ខុក.

១៣២- អសាធុំ សាធុនា ជិនេ

*បុគ្គលគប្បីឈ្នះមនុស្សមិនល្អ ដោយសេចក្ដីល្អ*

ខុ.ធ., ខុ.ជា. ខុក.

១៣៣- ជិនេ កទរិយំ ទានេន

*បុគ្គលគប្បីឈ្នះមនុស្សកំណាញ់ស្វិតស្វាញ ដោយការឲ្យ*

ខុ.ធ., ខុ.ជា. ខុក.

១៣៤- សច្ចេនាលិកវាទិនំ

*បុគ្គលគប្បីឈ្នះមនុស្សនិយាយមិនពិត ដោយពាក្យពិត*

ខុ.ធ., ខុ.ជា. ខុក.

---

## ៩- ទានវគ្គ

*"ពួកធម៌និយាយអំពីទាន (អំណោយ)"*

១៣៥- ទានញ្ច យុទ្ធញ្ច សមានមាហុ

*លោកពោលថា ទាននឹងចំបាំងស្មើគ្នា*

សំ.ស., ខុ.ជា.អដ្ឋក.

១៣៦– នត្ថិ ចិត្តេ បសន្នម្ហិ អប្បកា នាម ទក្ខិណា

*កាលបើចិត្តជ្រះថ្លាហើយ ទក្ខិណា ទានមិនឈ្មោះថាតិចតួចឡើយ*

ខុ. វិ.

១៣៧– វិចេយ្យ ទានំ សុគតប្បសត្ថំ

*ការពិចារណាហើយឲ្យ ព្រះសុគតទ្រង់សរសើរ*

សំ. ស., ខុ. ជា. អដ្ឋក., ខុ. បេត.

១៣៨– ពាលា ហវេ នប្បសំសន្តិ ទានំ

*បុគ្គលពាលទាំងឡាយ មិនសរសើរនូវទានឡើយ*

ខុ. ធ.

១៣៩– ទទំ មិត្តានិ គន្ថតិ

*អ្នកឲ្យ រមែងចងពួកមិត្របាន*

សំ. ស.

១៤០– ទទំ បិយោ ហោតិ ភជន្តិ នំ ពហូ

*អ្នកឲ្យរមែងជាទីស្រឡាញ់, មនុស្សទាំងឡាយច្រើន*

*តែងគប់រកនូវអ្នកឲ្យនោះ*

អង្គ. បញ្ចក.

១៤១– ទទមានោ បិយោ ហោតិ

*អ្នកឲ្យ រមែងជាទីស្រឡាញ់ (នៃជនដទៃ)*

អង្គ. បញ្ចក.

១៤២- សុខស្ស ទាតា មេធាវី សុខំ សោ អធិគច្ឆតិ

*អ្នកមានប្រាជ្ញាជាអ្នកឲ្យនូវសេចក្តីសុខ (ដល់អ្នកឯទៀតហើយ)*

*លោករមែងបាននូវសេចក្តីសុខ (នោះមកខ្លួនវិញ)*

អង្គ. បញ្ចក.

១៤៣- មនាបទាយី លភតេ មនាបំ

*អ្នកឲ្យរបស់គាប់ចិត្ត រមែងបានរបស់គាប់ចិត្តវិញ*

អង្គ. បញ្ចក.

១៤៤- សេដ្ឋន្ទទោ សេដ្ឋមុបេតិ ឋានំ

*អ្នកឲ្យទីឋានដ៏ប្រសើរ រមែងដល់នូវទីឋានដ៏ប្រសើរ*

អង្គ. បញ្ចក.

១៤៥- អគ្គស្ស ទាតា លភតេ បុនគ្គំ

*អ្នកឲ្យវត្ថុដ៏លើស រមែងបាននូវវត្ថុដ៏លើសវិញ*

អង្គ. បញ្ចក.

១៤៦- ទទតោ បុញ្ញំ បវឌ្ឍតិ

*បុណ្យរមែងចំរើនដល់អ្នកឲ្យ*

ទី. មហា., ខុ. ឧ.

១៤៧- ទទេយ្យ បុរិសោ ទានំ

*បុរសគួរឲ្យនូវទាន*

ខុ. ជា. សត្តក.

## ១០– ទុក្ខវគ្គ

"ពួកធម៌និយាយអំពីទុក្ខ"

១៤៨– នត្ថិ ខន្ធសមា ទុក្ខា

*ទុក្ខទាំងឡាយ ស្មើដោយខន្ធមិនមាន*

ខុ. និ.

១៤៩– សង្ខារា បរមា ទុក្ខា

*សង្ខារទាំងឡាយ ជាទុក្ខ ក្រៃលែង*

ខុ. និ.

១៥០– ទុរាវាសា ឃរា ទុក្ខា

*ផ្ទះទាំងឡាយ មានការគ្រប់គ្រងមិនល្អ ជាទុក្ខ*

ខុ. និ.

១៥១– ទលិទ្ទិយំ ទុក្ខំ លោកេ

*សេចក្ដីទលិទ្រ ជាទុក្ខ ក្នុងលោក*

អង្គ. ឆក្ក.

១៥២– ឥណាទានំ ទុក្ខំ លោកេ

*ការជំពាក់បំណុលគេជាទុក្ខ ក្នុងលោក*

អង្គ. ឆក្ក.

១៥៣– ទុក្ខំ អនាថោ វិហរតិ

មនុស្សឥតទីពឹង តែងនៅជាទុក្ខ

អង្គ. ទសក.

១៥៤– ទុក្ខំ សេតិ បរាជិតោ

អ្នកចាញ់គេ តែងនៅជាទុក្ខ

សំ. ស., ខុ. ធ.

១៥៥– អកិញ្ចនំ នានុបតន្តិ ទុក្ខា

សេចក្តីទុក្ខទាំងឡាយ រមែងមិនធ្លាក់តាមនូវបុគ្គលដែលឥតកង្វល់

ខុ. ធ.

---

## ១១– ធម្មវគ្គ

" ពួកធម៌និយាយអំពីធម៌ "

១៥៦– ធម្មោ រហទោ អកទ្ទមោ

ធម៌ដូចអន្លង់ មិនមានភក់

ខុ. ជា. ឆក្ក.

១៥៧– មនោបុព្វង្គមា ធម្មា

ធម៌ទាំងឡាយ មានចិត្តជាប្រធាន

ខុ. ធ.

១៥៨- ធម្មោ ហិ ឥសិនំ ធជោ

ធម៌ហ្នឹងឯង ជាទង់ជ័យរបស់ឥសីទាំងឡាយ

សំ.និ., អង្គ. ចតុក្ក, ខុ. ជា. អសីតិ.

១៥៩- សតំ ធម្មោ ទុរន្វយោ

ធម៌របស់សប្បុរសទាំងឡាយ គេដឹងបានដោយលំបាក

សំ. ស, ខុ. ជា. ទុក., ខុ. ជា. ទសក.

១៦០- សតញ្ច ធម្មោ ន ជរំ ឧបេតិ

ធម៌របស់សប្បុរសទាំងឡាយ មិនចូលទៅកាន់ជរា

សំ. ស., ខុ. ធ., ខុ. ជា. អសីតិ.

១៦១- សទ្ធម្មោ សព្ភិ រក្ខិតោ

ព្រះសទ្ធម្ម ដែលសប្បុរសទាំងឡាយរក្សាទុក

ទី. មហា.

១៦២- ធម្មោ សុចិណ្ណោ សុខមាវហាតិ

ធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយតែងនាំសុខមកឲ្យ

សំ. ស., ខុ. សុ., ខុ. ជា. ទសក., ខុ. ថេរ.

១៦៣- សព្វំ សហិតោ ហោតិ សទ្ធម្មេ សុប្បតិដ្ឋិតោ

អ្នកតាំងមាំក្នុងព្រះសទ្ធម្មនោះ ឈ្មោះថាជាអ្នកទំនុកបំរើដល់ផង

ទាំងពួង

១៦៤– ធម្មប្បីតិ សុខំ សេតិ

អ្នកក្រេបធម៌ តែងនៅជាសុខ

ខុ. ធ.

១៦៥– ធម្មចារី សុខំ សេតិ

អ្នកប្រព្រឹត្តធម៌ តែងនៅជាសុខ

ខុ. ធ., ខុ. ឧ.

១៦៦– ធម្មោ ហវេ រក្ខតិ ធម្មចារឹ

ធម៌ហ្នឹងឯង តែងរក្សាអ្នកប្រព្រឹត្តធម៌

ខុ. ជា. ទសក., ខុ. ថេរ.

១៦៧– ន ទុគ្គតឹ គច្ឆតិ ធម្មចារី

អ្នកប្រព្រឹត្តធម៌ មិនទៅកាន់ទុគ្គតិ

ខុ. ជា. ទសក., ខុ. ថេរ.

១៦៨. ធម្មេ ឋិតំ ន វិជហាតិ កិត្តិ

កេរ្តិ៍ឈ្មោះមិនលះបង់បុគ្គលដែលតាំងនៅក្នុងធម៌ឡើយ

អង្គ. បញ្ចក.

១៦៩– ធម្មេ ឋិតា យេ ន ករោន្តិ បាបកំ

ពួកជនណាស្ថិតនៅក្នុងធម៌ ពួកជននោះមិនធ្វើនូវបាបទេ

អង្គ. ចតុក្ក.

១៧០- សព្វេ ធម្មា នាលំ អភិនិវេសាយ

មិនគួរប្រកាន់ធម៌ទាំងពួងស្អិតពេកឡើយ

ម. ម.

១៧១- យោនិសោ វិចិនេ ធម្មំ

បុគ្គលគប្បីពិចារណាធម៌ ដោយឧបាយ

ម. ឧ., សំ. ស., អង្គ. សត្តក.

១៧២- ធម្មញ្ចរេ សុចរិតំ

បុគ្គលគប្បីប្រព្រឹត្តនូវសុចរិតធម៌

ខុ. ធ., ខុ. ឧ.

១៧៣- សទ្ធម្មោ គរុកាតព្វោ

បុគ្គលគួរគោរពព្រះសទ្ធម្ម

អង្គ. ចតុក្ក.

១៧៤- កណ្ហំ ធម្មំ វិប្បហាយ

បណ្ឌិតគួរលះធម៌ខ្មៅចេញ

សំ. មហា., ខុ. ធ.

១៧៥- សុក្កំ ភាវេថ បណ្ឌិតោ

បណ្ឌិតគួរចំរើនធម៌ស

សំ. មហា., ខុ. ធ.

## ១២ – បកិណ្ណកវគ្គ

" ពួកធម៌កយារ៍ "

១៧៦– អដ្ឋង្គិកោ ច មគ្គានំ ខេមំ អមតគាមិនំ

បណ្តាផ្លូវទាំងឡាយ ផ្លូវមានអង្គ៨ ជាផ្លូវឲ្យដល់អមតធម៌ក្សេម

ម. ម.

១៧៧– យំ កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មំ

របស់ណាមួយ មានកិរិយាកើតឡើងជាធម្មតា របស់ទាំងអស់

នោះ មានកិរិយារលត់ទៅវិញជាធម្មតា

សំ. មហា.

១៧៨– អារោគ្យបរមា លាភា

ការមិនមានរោគ ជាលាភដ៏ក្រៃលែង

ម. ម., ខុ. ធ.

១៧៩– ជិឃច្ឆា បរមា រោគា

សេចក្តីឃ្លាន ជារោគដ៏ក្រៃលែង

ខុ. ធ.

១៨០– សង្ខារា សស្សតា នត្ថិ

សង្ខារទាំងឡាយ ឥតទៀងទាត់ទេ

ខុ. ធ.

១៨១- អនិច្ចា វត សង្ខារា

ឱហ្ន៎! សង្ខារទាំងឡាយ មិនទៀងសោះឡើយ!

ទី. មហា., សំ. ស., សំ. និ.

១៨២- ទុល្លភា ខណសម្បត្តិ

ការដល់ព្រមនៃខណៈ គេបានដោយកម្រ

ក. ក.

១៨៣- ទុល្លភំ ទស្សនំ ហោតិ សម្ពុទ្ធានំ អភិណ្ហសោ

ការឃើញនូវព្រះសម្ពុទ្ធទាំងឡាយរឿយៗ ជាការបានដោយកម្រ

ម. ម. ខុ. សុ.

១៨៤- ខណោ វោ មា ឧបច្ចគា

ខណៈ កុំកន្លងនូវអ្នកទាំងឡាយឡើយ

អង្គ. អដ្ឋក., ខុ. ធ., ខុ. សុ.

១៨៥- អតិបតតិ វយោ ខណោ តថេវ

វ័យតែងកន្លងហួសទៅ ដូចគ្នានឹងខណៈដែរ

ខុ. ជា. ឯក.

១៨៦- កាលោ ឃសតិ ភូតានិ សព្វានេវ សហត្តនា

កាលវេលាតែងស៊ីនូវពួកសត្វទាំងអស់ព្រមទាំងខ្លួនឯងផង

ខុ. ជា. ទុក.

១៨៧– ឥតិ វិស្សជ្ជកម្មន្តេ អត្ថា អច្ចេន្តិ មាណវេ

ប្រយោជន៍ទាំងឡាយតែងកន្លងនូវមនុស្សទាំងឡាយ ដែលមានការងារលះបង់ហើយ

ទី. ៣ង.

១៨៨– នក្ខត្តំ បដិមានេន្តំ អត្ថោ ពាលំ ឧបច្ចគា

ប្រយោជន៍កន្លងហើយ នូវមនុស្សល្ងង់ ដែលរាប់អាននូវនក្ខត្តឫក្ស

ខុ. ជា. ឯក.

១៨៩– អត្ថោ អត្ថស្ស នក្ខត្តំ កឹ ករិស្សន្តិ តារកា

ប្រយោជន៍ជានក្ខត្តឫក្សរបស់ប្រយោជន៍ទេតើ ផ្កាយទាំងឡាយនឹងធ្វើអ្វីឲ្យ!

ខុ. ជា. ឯក.

១៩០– វសោ ឥស្សរិយំ លោកេ

អំណាចជាធំក្នុងលោក

សំ. ស.

១៩១– សិរី ភោគានមាសយោ

សិរី ជាដំណាក់នៃភោគៈទាំងឡាយ

សំ. ស.

១៩២- កិច្ឆា វុត្តិ អសិប្បស្ស

ការប្រព្រឹត្តិរបស់បុគ្គលមិនមានសិប្បៈ ជាការលំបាក

ខុ. ជា. ទុកស.

១៩៣- សាធុ ខោ សិប្បកំ នាម អបិ យាទិសកីទិសំ

ធម្មតាសិប្បៈទោះបីរប៉ិចរប៉ុចសោះទេ ក៏គង់ញុំាងប្រយោជន៍ឲ្យ

សម្រេចបានដែរ

ខុ. ជា. ឯក.

១៩៤- សព្វញ្ចេ បឋវឹ ទជ្ជា នាកតញ្ញុំ អភិរាធយេ

បើទុកជាប្រគល់នូវផែនដីទាំងមូលឲ្យ ក៏ធ្វើបុគ្គលអកតញ្ញូឲ្យ

ត្រេកអរមិនបានឡើយ

ខុ. ជា. ឯក.

១៩៥- ហន្តិ ភោគា ទុម្មេធំ

ភោគៈទាំងឡាយ តែងសម្លាប់មនុស្សឥតបញ្ញា

ខុ. ធ.

១៩៦- សក្ការោ កាបុរិសំ ហន្តិ

សក្ការៈ តែងសម្លាប់បុរសអាក្រក់

វិ. ចុល. សំ. ស., សំ. និ.

១៩៧ – កិច្ឆោ មនុស្សប្បដិលាភោ

ការបានជាតិជាមនុស្ស ជាការក្រ

ខុ. ធ.

១៩៨ – កិច្ឆំ មច្ចាន ជីវិតំ

ការរស់នៅរបស់សត្វទាំងឡាយ ជាការក្រ

ខុ. ធ.

១៩៩ – កិច្ឆំ សទ្ធម្មស្សវនំ

ការស្តាប់ធម៌របស់សប្បុរស ជាការក្រ

ខុ. ធ.

២០០ – កិច្ឆោ ពុទ្ធានមុប្បាទោ

ការកើតឡើង នៃលោកអ្នកត្រាស់ដឹងទាំងឡាយ ជាការក្រ

ខុ. ធ.

២០១ – អសជ្ឈាយមលា មន្តា

មន្តទាំងឡាយ មានការមិនស្វាធ្យាយជាមន្ទិល

អង្គ. អដ្ឋក., ខុ. ធ.

២០២ – អនុដ្ឋានមលា ឃរា

ផ្ទះទាំងឡាយ មានការមិនជួសជុលជាមន្ទិល

អង្គ. បញ្ចក., ខុ. ធ.

២០៣- មល៍ វណ្ណស្ស កោសជ្ជំ

សេចក្តីខ្ជិល ជាមន្ទិលនៃពណ៌សម្បុរ

អង្គ. អដ្ឋក., ខុ. ធ.

២០៤- មលិត្ថិយា ទុច្ចរិតំ

ទុច្ចរិតជាមន្ទិលរបស់ស្ត្រី

អង្គ. អដ្ឋក., ខុ. ធ.

២០៥- សុទ្ធិ អសុទ្ធិ បច្ចត្តំ

សេចក្តីបរិសុទ្ធ និងមិនបរិសុទ្ធ មានចំពោះខ្លួន

ខុ. ធ., ខុ. មហា., ខុ. ចូ.

២០៦- នាញ្ញោ អញ្ញំ វិសោធយេ

អ្នកដទៃធ្វើអ្នកដទៃឲ្យបរិសុទ្ធមិនបានទេ

ខុ. ធ., ខុ. មហា., ខុ. ចូ.

២០៧- សុទ្ធស្ស សុចិកម្មស្ស សទា សម្បជ្ជតេ វតំ

វត្តតែងសម្រេចដល់អ្នកបរិសុទ្ធ មានការងារស្អាតសព្វ ៗ កាល

ម. ម.

២០៨- សុទស្សំ វជ្ជមញ្ញេសំ អត្តនោ បន ទុទ្ទសំ

ទោសរបស់ជនទាំងឡាយដទៃងាយឃើញ ចំណែកខាងទោស

របស់ខ្លួនវិញមិនងាយឃើញទេ

ខុ. ធ..

២០៩- នត្ថិ លោកេ រហោ នាម បាបកម្មំ បកុព្វតោ

ឈ្មោះថាទីស្ងាត់របស់អ្នកធ្វើបាបកម្មមិនមានក្នុងលោកសោះឡើយ

អង្គ. តិក., ១. ជា. ចតុក្ក.

២១០- នេសា សភា យត្ថ ន សន្តិ សន្តោ

សប្បុរសទាំងឡាយ មិនមានក្នុងទីប្រជុំណា ទីប្រជុំនោះ មិនឈ្មោះ

ជាសភាឡើយ

សំ. ស., ១. ជា. អសីតិ.

២១១- ភោគា សន្និចយំ យន្តិ វម្មិកោវូបចីយតិ

ភោគៈទាំងឡាយ (របស់អ្នកគ្រប់គ្រងផ្ទះល្អ) រមែងដល់នូវកិរិយាកកូន

ដូចជាដំបូកដែលកណ្ដៀរពូនឡើង

ទី ឃនិ.

២១២- អលំ ពាលស្ស មោហាយ នោ ច បារគវេសិនោ

រូបនោម អាចធ្វើមនុស្សល្ងង់ឲ្យវង្វេងបាន តែមិនអាចធ្វើមនុស្សអ្នក

ស្វែងរកព្រះនិព្វានឲ្យវង្វេងបានឡើយ

ម. ម. ១. ថេរ.

២១៣- រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ

រូបរបស់សត្វទាំងឡាយតែងគ្រាំគ្រា ឯនាមនិងគោត្រមិនចេះគ្រាំគ្រាឡើយ

សំ. ស.

២១៤- ចីនំ ភាវោ ទុរាជានោ

ភាពរបស់ស្រីទាំងឡាយ គេដឹងបានដោយក្រ

ខុ. ជា. ឯក.

២១៥- ឧក្កដ្ឋេ សូរមិច្ឆន្តិ

ក្នុងកាលសង្គ្រាម តែងត្រូវការមនុស្សក្លៀវក្លា

ខុ. ជា. ឯក.

២១៦- មន្តីសុ អកុតូហលំ

ក្នុងវេលាប្រឹក្សា តែងត្រូវការមនុស្សដែលមិននិយាយឥតប្រយោជន៍

ខុ. ជា. ឯក.

២១៧- បិយញ្ច អន្នបានម្ហិ

ក្នុងគ្រាបានបាយទឹក រមែងត្រូវការមនុស្សជាទីស្រឡាញ់

ខុ. ជា. ឯក.

២១៨- អត្ថេ ជាតេ ច បណ្ឌិតំ

កាលអាថ៌ប្រស្នាកើតឡើង រមែងត្រូវការបណ្ឌិត

ខុ. ជា. ឯក.

២១៩- អាបទាសុ ថាមោ ឥច្ឆិតព្វោ

កម្លាំងចិត្ត គប្បីដឹងបានក្នុងវេលាមានអន្តរាយ

ខុ. ជា.

២២០- យសោ លទ្ធា ន មជ្ជេយ្យ

បុគ្គលបានយសហើយ មិនគួរស្រវឹងឡើយ

ខុ. ជា. ចតុក្ក.

២២១- ចាគមនុព្រូហយេ

គប្បីចំរើននូវចាគៈ

ម. ឧ.

២២២- សន្តិមេវ សិក្ខេយ្យ

គប្បីសិក្សាសេចក្តីស្ងប់ តែឲ្យមែនទែន

ម. ឧ.

២២៣- លោកាមិសំ បជហេ សន្តិបេក្ខោ

អ្នកសំឡឹងនូវសេចក្តីស្ងប់ គប្បីលះអាមិសក្នុងលោក

សំ. ស.

២២៤- តំ គណ្ហេយ្យ យទបណ្ណកំ

របស់ណាមិនខុស គប្បីកាន់យករបស់នោះ

ខុ. ជា. ឯក.

២២៥- សនាថា វិហរថ មា អនាថា

អ្នកទាំងឡាយចូរនៅមានទីពឹង កុំនៅឥតទីពឹងឡើយ

អង្គ. ទសក.

២២៦- ធាញ្ញំ និស្សាយ ជីវេយ្យ

*មិនគួររស់នៅអាស្រ័យបុគ្គលដទៃទេ*

ខុ. ន.

២២៧- អារោគ្យមិច្ឆេ បរមញ្ច លាភំ

*បុគ្គលគប្បីបង់បាននូវការមិនមានរោគ ដែលជាលាភយ៉ាងក្រៃលែង*

ខុ. ជា. ឯក.

២២៨- អតីតំ នាន្វាគមេយ្យ

*មិនគួរនឹកដល់របស់ដែលកន្លងទៅហើយទេ*

ម. ឧ

២២៩- នប្បដិកង្ខេ អនាគតំ

*មិនគួរបង់បានរបស់ដែលមិនទាន់មកដល់ឡើយ*

ម. ឧ.

---

## ១៣- បញ្ញាវគ្គ

*"ពួកធម៌និយាយអំពីបញ្ញា"*

២៣០- អយោគា ភូរិសង្ខយោ

*ការអស់បញ្ញា ព្រោះមិនមានព្យាយាម*

ខុ. ធ.

២៣១- ឯកោ វ សេយ្យោ បុរិសោ សបញ្ញោ
យោ ភាសិតស្ស វិជានាតិ អត្ថំ

*បុរសណាដឹងច្បាស់នូវសេចក្តីនៃភាសិត បុរសនោះជាអ្នកមានបញ្ញា សូម្បីម្នាក់ឯងក៏គង់ប្រសើរជាង*

ខុ. ជា. ឯក.

២៣២- តថត្តានំ និវេសេយ្យ យថា ភូរិ បវឌ្ឍតិ

*បញ្ញាចំរើនឡើងបែបណា គួរតាំងខ្លួនបែបនោះ*

ខុ. ធ.

២៣៣- នត្ថិ ឈានំ អបញ្ញស្ស

*ការពិនិត្យ មិនមានដល់បុគ្គលឥតបញ្ញា*

ខុ. ធ.

២៣៤- នត្ថិ បញ្ញាសមា អាភា

*ពន្លឺស្មើដោយបញ្ញា មិនមាន*

សំ. ស.

២៣៥- បញ្ញំ នប្បមជ្ជេយ្យ

*បុគ្គល មិនគួរប្រមាទនូវបញ្ញាឡើយ*

ម. ឧ.

២៣៦- បញ្ញា បេតំ បសាសតិ

បញ្ញា តែងគ្រប់គ្រងនូវបុរសនោះ

ស. ស.

២៣៧- បញ្ញាជីវីជីវិតមាហ សេដ្ឋំ

អ្នកប្រាជ្ញទាំងឡាយ លោកពោលជីវិតរបស់អ្នករស់នៅដោយបញ្ញាថា ប្រសើរបំផុត

សំ. ស., ខុ. សុ.

២៣៨- បញ្ញា នត្ថិ អឈាយតោ

បញ្ញាមិនមានដល់អ្នកដែលមិនពិនិត្យ

ខុ. ធ.

២៣៩- នរានំ រតនំ បញ្ញា

បញ្ញា ជារតនៈ របស់នរជនទាំងឡាយ

សំ. ស.

២៤០- បញ្ញាយត្ថំ វិបស្សតិ

បុគ្គលឃើញច្បាស់នូវសេចក្តី (របស់ធម៌) ដោយបញ្ញា

អង្គ. សត្តក.

២៤១- បញ្ញាយ បរិសុជ្ឈតិ

បុគ្គលបរិសុទ្ធ ដោយសារបញ្ញា

ខុ. សុ.

២៤២- បញ្ញាយ មគ្គំ អលសោ ន វិន្ទតិ

មនុស្សខ្ជិលមិនបានផ្លូវនៃបញ្ញាឡើយ

ខុ. ធ.

២៤៣- បញ្ញា លោកស្មិ បជ្ជោតោ

បញ្ញា ជាពន្លឺ ក្នុងលោក

សំ. ស.

២៤៤- បញ្ញា វ ធនេន សេយ្យោ

បញ្ញាហ្នឹងឯង ប្រសើរជាងទ្រព្យ

ម. ម., ខុ. ថេរ.

២៤៥- បញ្ញា ហិ សេដ្ឋា កុសលា វទន្តិ

អ្នកឈ្លាសវៃទាំងឡាយ តែងពោលថាបញ្ញាហ្នឹងឯង ប្រសើរបំផុត

ខុ. ជា. សត្តក.

២៤៦- ពហូនំ វត អត្ថាយ សប្បញ្ញោ ឃរមាវសំ

អ្នកមានបញ្ញានៅគ្រប់គ្រងផ្ទះ ដើម្បីប្រយោជន៍ដល់មនុស្សច្រើន

អង្គ. អដ្ឋក.

២៤៧- យោគា វេ ជាយតី ភូរិ

ប្រាជ្ញាតែងកើត ព្រោះសេចក្ដីព្យាយាម

ខុ. ធ.

២៤៨- សាកច្ឆាយ បញ្ញា វេទិតព្វា

បញ្ញា គេត្រូវដឹងបាន ដោយសាកច្ឆា

ខុ. ឧ.

២៤៩- សុខោ បញ្ញាបដិលាភោ

ការបាននូវបញ្ញា នាំមកនូវសេចក្ដីសុខ

ខុ. ជ.

២៥០- សុស្សូសំ លភតេ បញ្ញំ

អ្នកស្ដាប់ល្អ រមែងបានបញ្ញា

សំ. ស., ខុ. សុ.

---

## ១៤- បមាទវគ្គ

" ពួកធម៌និយាយអំពីសេចក្ដីប្រមាទ "

២៥១- តេ ទីឃរត្តំ សោចន្តិ  យេ បមជ្ជន្តិ មាណវា

មាណពទាំងឡាយណាប្រមាទ មាណពទាំងឡាយនោះ

តែងសោយសោកអស់កាលយូរ

ម. ឧ.

២៥២ បមាទមនុយុញ្ជន្តិ ពាលា ទុម្មេធិនោ ជនា

*ជនពាលទាំងឡាយឥតបញ្ញា តែងប្រកបរឿយ ៗ នូវសេចក្ដីប្រមាទ*

ម. ម., សំ. ស., ខុ. ធ.

២៥៣– បមាទេន ន សំវសេ

*បុគ្គលមិនគួរសមគប់ ដោយសេចក្ដីប្រមាទ*

ខុ. ធ., ខុ. ស., ខុ. មហា.

២៥៤– បមាទោ គរហិតោ សទា

*សេចក្ដីប្រមាទ បណ្ឌិតតិះដៀលគ្រប់កាល*

ខុ. ធ.

២៥៥– បមាទោ មច្ចុនោ បទំ

*សេចក្ដីប្រមាទ ជាផ្លូវនៃសេចក្ដីស្លាប់*

ខុ. ធ., ខុ. ជា. តឹស.

២៥៦– បមាទោ រក្ខតោ មលំ

*សេចក្ដីប្រមាទ ជាមន្ទិលរបស់អ្នករក្សា*

អង្គ. អដ្ឋក., ខុ. ធ.

២៥៧– មា បមាទមនុយុញ្ជេថ

*ចូរកុំប្រកបរឿយ ៗ នូវសេចក្ដីប្រមាទ*

ម. ម., បេ. វ., ខុ. ធ.

២៥៨– យេ បមត្តា យថា មតា

*ពួកជនណាប្រមាទ ពួកជននោះទុកដូចជាស្លាប់*

ខុ. ធ., ខុ. ជា. តឹស.

---

## ១៥– បាបវគ្គ

*" ពួកធម៌និយាយអំពីបាប "*

២៥៩– តបសា បជហន្តិ បាបកម្មំ

*សាធុជនទាំងឡាយ តែងលះបង់បាបកម្មដោយតបៈ*

ខុ. ជា. អដ្ឋក.

២៦០– ទុក្ខោ បាបស្ស ឧច្ចយោ

*ការសន្សំបាប នាំមកនូវសេចក្ដីទុក្ខ*

ខុ. ធ.

២៦១– ធម្មំ មេ ភណមានស្ស ន បាបមុបលិម្បតិ

*បាបមិនជិតជាមជល់អាត្មាអញដែលពោលនូវធម៌*

ខុ. ជា. សត្តក

២៦២– ន ឃាសហេតុបិ ករេយ្យ បាបំ

*បុគ្គលមិនគួរធ្វើបាបព្រោះហេតុតែការស៊ីឡើយ*

ខុ. ជា. ឆក.

២៦៣- នត្ថិ អការិយំ បាបំ មុសាវាទិស្ស ជន្តុនោ

មនុស្សអ្នកនិយាយកុហក ឈ្មោះថាមិនធ្វើអំពើ

អាក្រក់ឥតអ្វីមានឡើយ

ខុ. ធ., ខុ. ឥតិ.

២៦៤- នត្ថិ បាបំ អកុព្វតោ

បាបមិនមានដល់អ្នកមិនធ្វើ

ខុ. ធ.

២៦៥- បាបំ បាបេន សុករំ

អំពើអាក្រក់ មនុស្សអាក្រក់ធ្វើបានដោយងាយ

វិ. ចុល., ខុ. ឧ.

២៦៦- បាបានំ អករណំ សុខំ

ការមិនធ្វើបាបទាំងឡាយ នាំមកនូវសេចក្ដីសុខ

ខុ. ធ.

២៦៧- បាបានិ កម្មានិ ករោន្តិ មោហា

ពួកមនុស្សតែងធ្វើនូវបាបកម្មទាំងឡាយ ព្រោះ

សេចក្ដីល្ងង់

ម. ប., ខុ. ជា. បកិណ្ណក.

២៦៨- បាបានិ បរិវជ្ជយេ

*បុគ្គលគប្បីវៀរបង់នូវបាបទាំងឡាយ*

ខុ. ធ.

២៦៩- បាបេន រមតី សុចិ

*មនុស្សស្អាត មិនត្រេកអរ ក្នុងសេចក្តីអាក្រក់*

វិ. មហា., ខុ. ឧ.

២៧០- មលា វេ បាបកា ធម្មា អស្មឹ លោកេ បរម្ហិ ច

*បាបធម៌ទាំងឡាយជាមន្ទិលពិត ក្នុងលោកនេះផង .*

*លោកខាងមុខ*

អង្គ. អដ្ឋក., ខុ. ធ.

២៧១- សកម្មុនា ហញ្ញតិ បាបធម្មោ

*មនុស្សមានសន្តានអាក្រក់ រមែងលំបាក ព្រោះ*

*កម្មរបស់ខ្លួន*

ម. ម., ខុ. ថេរ.

---

## ១៦–បុគ្គលវគ្គ

"ពួកធម៌និយាយអំពីបុគ្គល"

២៣២– អតិតិក្ខោ ច វេរវា

*មនុស្សអត់ធ្មត់ពេក ជាអ្នកមានពៀរ*

ខុ. ជា. ទ្វាទស.

២៣៣– អធុរាយំ ន យុញ្ជតិ

*អ្នកមានបញ្ញា រមែងមិនប្រកបក្នុងកិច្ចដែលមិនមែនជាធុរៈ*

ខុ. ជា. តេរស.

២៣៤– អធុរាយំ និយុញ្ជតិ

*អ្នកឥតបញ្ញា រមែងប្រកបក្នុងកិច្ចដែលមិនមែនជាធុរៈ*

ខុ. ជា. តេរស.

២៣៥– អនត្ថំ បរិវជ្ជេតិ  អត្ថំ គណ្ហាតិ បណ្ឌិតោ

*បណ្ឌិតតែងវៀរចេញនូវអំពើដែលឥតប្រយោជន៍ កាន់យកតែអំពើដែលជាប្រយោជន៍*

អង្គ. ចតុក្ក.

២៣៦– អនយំ នយតិ ទុម្មេធោ

*មនុស្សឥតប្រាជ្ញា តែងណែនាំផ្លូវដែលមិនគួរណែនាំ*

ខុ. ជា. តេរស.

២៧៧– អនុបាទា វិមុច្ចន្តិ

ពួកសាធុជនតែងផុតស្រឡះ ព្រោះសេចក្តីមិនប្រកាន់មាំ

ម. នុ. អង្គ. តិក.

២៧៨– អនុបាយេន យោ អត្ថំ ឥច្ឆតិ សោ វិហញ្ញតិ

អ្នកណាចង់បានប្រយោជន៍ដោយគ្មានឧបាយ អ្នកនោះរមែងលំបាក

ខុ. ជា. ឯក.

២៧៩– អសន្តេត្ថ ន ទិស្សន្តិ

ពួកអសប្បុរស មិនប្រាកដក្នុងទីនេះ

ខុ. ធ.

២៨០– អសន្តោ និរយំ យន្តិ

ពួកអសប្បុរសតែងទៅនរក

សំ. ស., ខុ. ជា. ទុក.

២៨១– អាហុនេយ្យា ច បុត្តានំ

មាតាបិតា ជាអ្នកគួរដល់ការបូជារបស់កូនទាំងឡាយ

អង្គ. តិក. អង្គ. ចតុក្ក., ខុ. ឥតិ.

២៨២– ឥត្ថី ភណ្ឌានមុត្តមំ

ស្ត្រីជាទ្រព្យខ្ពង់ខ្ពស់ជាងភណ្ឌៈទាំងឡាយ

សំ. ស.

២៨៣- ឥត្ថី មលំ ព្រហ្មចរិយស្ស

*ស្ត្រីជាមន្ទិលរបស់ព្រហ្មចារ្យ*

សំ. ស.

២៨៤- ឥន្ទ្រិយានិ រក្ខន្តិ បណ្ឌិតា

*ពួកបណ្ឌិត តែងរក្សានូវឥន្ទ្រិយទាំងឡាយ*

ទី. មហា., សំ. ស.

២៨៥- ឧជ្ឈត្តិពលា ពាលា

*ជនពាលទាំងឡាយ មានការលើកទោសជាកម្លាំង*

អង្គ. អដ្ឋក.

២៨៦- ឧបសន្តោ សុខំ សេតិ

*អ្នកស្ងប់រម្ងាប់តែងនៅជាសុខ*

វិ. ចូល., សំ. ស., អង្គ. តិក.

២៨៧- កវិ គាថានមាសយោ

*ចិន្តកវី ជាទីអាស្រ័យនៃគាថាទាំងឡាយ*

សំ. ស.

២៨៨- កុសលោ ច ជហាតិ បាបកំ

*មនុស្សឈ្លាស តែងលះបង់នូវបាប*

ទី. មហា., ខុ. ឧ.

២៨៩- គរុ ហោតិ សគារវោ

អ្នកគោរពគេ តែងមានគេគោរពវិញ

ខុ. ជា. មហា.

២៩០- ចោរា លោកស្មិមុបទ្ទវា

ពួកចោរ ជាមនុស្សបំផ្លាញក្នុងលោក

សំ. ស.

២៩១- ទន្តោ សេដ្ឋោ មនុស្សេសុ

មនុស្សមានខ្លួនទូន្មានហើយ ប្រសើរបំផុតជាងមនុស្សទាំងឡាយ

ខុ. ធ., ខុ. មហា., ខុ. ចូ.

២៩២- ទុដ្ឋោបិ ពហុភាសតិ

មនុស្សតែក្រោធហើយ និយាយច្រើន

ខុ. ជា. ទ្វាទស.

២៩៣- ទុល្លភោ អង្គសម្បន្នោ

អ្នកដល់ព្រមដោយអង្គគុណ គេរកបានដោយលំបាក

ខុ. ជា. ទុក.

២៩៤- ទុល្លភោ បុរិសាជញ្ញោ

បុរសអាជានេយ្យ គេរកបានដោយកម្រ

ខុ. ធ.

២៩៥- ទូរេ សន្តោ បកាសេន្តិ

សប្បុរសទាំងឡាយតែងប្រាកដក្នុងទីឆ្ងាយ

ខុ. ធ.

២៩៦- ធម្មកាមោ ភវំ ហោតិ

អ្នកស្រឡាញ់ធម៌ ជាមនុស្សចំរើន

ខុ. សុ.

២៩៧- ធម្មទេស្សី បរាភវោ

អ្នកស្អប់ធម៌ ជាមនុស្សវិនាស

ខុ. សុ.

២៩៨- ធីរោ ច ពលវា សាធុ យូថស្ស បរហារកោ

អ្នកប្រាជ្ញមានកម្លាំងរក្សានូវពួក ឲ្យសម្រេចប្រយោជន៍បាន

ខុ. ជា. សត្តក.

២៩៩- ធីរោ ភោគេ អធិគម្ម សង្គណ្ហាតិ ច ញាតកេ

អ្នកប្រាជ្ញបានភោគៈទាំងឡាយហើយ តែងសង្គ្រោះនូវញាតិទាំងឡាយ

ខុ. ជា. ឆក្ក.

៣០០- ន ឧច្ចាវចំ បណ្ឌិតា ទស្សយន្តិ

ពួកបណ្ឌិតរមែងមិនសំដែង នូវអាការខ្ពស់ទាប

ខុ. ធ.

៣០១- ន ឧជ្ឈត្តា វិតថំ ភណន្តិ

មនុស្សក្រន់ទាំងឡាយ មិនទំលោយឲ្យឃ្លាតសេចក្តីពិតឡើយ

ខុ. ជា. បក្ក.

៣០២- ន កាមកាមា លបយន្តិ សន្តោ

សប្បុរសទាំងឡាយ មិនបរបាព្រោះប្រាថ្នានូវកាម

ខុ. ធ.

៣០៣- នត្ថិ លោកេ អនិន្ទិតោ

ក្នុងលោក ឥតមានអ្នកដែលគេមិននិន្ទាឡើយ

ខុ. ធ.

៣០៤- នយំ នយតិ មេធាវី

អ្នកមានបញ្ញា តែងនាំនូវផ្លូវដែលគួរនាំ

ខុ. ជា. តេរស.

៣០៥- ន សាធុ ពលវា ពាលោ យូថស្ស បរិហារកោ

ជនពាលមានកម្លាំងគ្រងនូវពួក ឲ្យសម្រេចប្រយោជន៍មិនបានឡើយ

ខុ. ជា. សត្តក.

៣០៦- និជ្ឈត្តិពលា បណ្ឌិតា

បណ្ឌិតទាំងឡាយ មានការមិនសំឡឹងទោសជាកម្លាំង

អង្គ. អដ្ឋក.

៣០៧- នេកាសី លភតេ សុខំ

អ្នកស៊ីម្នាក់ឯង មិនបានសេចក្ដីសុខទេ

ខុ. ជា. ទ្វាទសក.

៣០៨- បដិសង្ខានពលា ពហុស្សុតា

ពួកពហុស្សុត មានការពិចារណាជាកម្លាំង

អង្គ. អដ្ឋក.

៣៩០- បណ្ឌិតោ សីលសម្បន្នោ ជលំ អគ្គីវ ភាសតិ

បណ្ឌិតបរិបូណ៌ដោយសីល រមែងរុងរឿងដូចភ្លើងភ្លឺ

ទី. បាធិ.

៣១០- បរិភូតោ មុទុ ហោតិ

មនុស្សទន់ ត្រូវគេមើលងាយ

ខុ ជា. ទ្វាទស.

៣១១- បុត្តា វត្ថុ មនុស្សានំ

កូនទាំងឡាយ ជាវត្ថុរបស់ពួកមនុស្ស

សំ. ស.

៣១២- បុព្វាចរិយាតិ វុច្ចរេ

មាតានិងបិតា លោកហៅថាបុព្វាចារ្យ (របស់បុត្រ)

អង្គ. តិក., អង្គ. ចតុក្ក., ខុ. ឥតិ.

៣១៣- បូជកោ លភតេ បូជំ

*អ្នកបូជាគេ រមែងបានទទួលការបូជាវិញ*

ខុ. ជា. មហា.

៣១៤- ផាតិ កយិរា អវិហេឋយំ បរំ

*គួរធ្វើតែសេចក្ដីចំរើន កុំបៀតបៀនអ្នកដទៃឡើយ*

ខុ. ជា.. សត្តក.

៣១៥- ពហុម្បិ រត្តោ ភាសេយ្យ

*មនុស្សត្រេកអរ ហើយនិយាយច្រើន*

ខុ. ជា. ភូទសក.

៣១៦- ព្រហ្មាតិ មាតាបិតរោ

*មាតានឹងបិតាលោកហៅថា ព្រហ្ម (របស់បុត្រ)*

អង្គ. តិក., អង្គ. ចតុក្ក., ខុ. ឥតិ

៣១៧- ពាលោ អបរិណាយកោ

*មនុស្សពាល មិនគួរជាអ្នកនាំមុខគេទេ*

ខុ. ជា. ទុក.

៣១៨- ភត្តា បញ្ញាណមិត្ថិយា

*ភត្តា ជាគ្រឿងប្រាកដរបស់ស្ត្រី*

សំ. ស.

៣១៩- កតញ្ញុំ គរុនោ សព្វេ បដិបូជេន្តិ បណ្ឌិតា

*ពួកគរុ យា ជាបណ្ឌិត តែងរាប់អានប្ដី នឹងមនុស្សដែលគួរគោរពទាំងពួង*

អង្គ. អដ្ឋក

៣២០- មហាការុណិកោ នាថោ

*លោកអ្នកប្រកបដោយករុណាធំ តែងជាទីពឹងគេ*

ក. ក.

៣២១- យថាវាទី តថាការី

*និយាយយ៉ាងណា ធ្វើយ៉ាងនោះ*

ទី. មហា., ខុ. សុ., ខុ. ថេរ., ខុ. ជា. ចតុក្ក.

៣២២- យោ ច បុត្តានមស្សវោ

*បណ្ដាបុត្រទាំងឡាយ បុត្រណាជឿស្ដាប់ (បុត្រនោះប្រសើរ)*

សំ. ស.

៣២៣- យោ ពាលោ មញ្ញតី ពាល្យំ

បណ្ឌិតោ វាបិ តេន សោ

*ជនពាលណា សំគាល់ថាខ្លួនពាល ជនពាលនោះ ហៅ*

*ជាបណ្ឌិត ដោយហេតុនោះក៏បាន*

ខុ. ធ.

៣២៤- **រក្ខេយ្យានាគតំ ភយំ**

*គប្បីរក្សានូវភ័យ ដែលមិនទាន់មកដល់*

ខុ. ជា. បក្ក.

៣២៥- **វន្ទកោ បដិវន្ទំ**

*អ្នកសំពះ រមែងបានទទួលការសំពះតប*

ខុ. ជា. មហា.

៣២៦- **វិស្សាសបរមា ញាតី**

*សេចក្តីស្និទ្ធស្នាល ជាញាតិយ៉ាងក្រៃលែង*

ខុ. ធ.

៣២៧- **សក្កត្វា សក្កតោ ហោតិ**

*អ្នកធ្វើសក្ការៈ រមែងជាអ្នកដែលគេធ្វើសក្ការៈវិញ*

ខុ. ជា. មហា.

៣២៨- **សតញ្ច គន្ធោ បដិវាតមេតិ**

*ក្លិនរបស់សប្បុរសទាំងឡាយ តែងផ្សាយទៅច្រាស*

*ខ្យល់បាន*

អង្គ. តិក., ខុ. ធ.

៣២៩- សន្តោ ន តេ យេ ន វទន្តិ ធម្មំ

*ជនទាំងឡាយណាមិននិយាយនូវធម៌ ជនទាំងឡាយនោះ មិនមែនជាសប្បុរសទេ*

សំ. ស.

៣៣០- សន្តោ សគ្គបរាយណា

*សប្បុរសទាំងឡាយ មានឋានសួគ៌ជាទីប្រព្រឹត្តទៅក្នុងខាងមុខ*

សំ. ស., ខុ. ជា. ទុក.

៣៣១- សន្តោ សត្តហិតេ រតា

*សប្បុរសទាំងឡាយ ត្រេកអរក្នុងការទំនុកបំរុងសត្វ*

ជាតកដ្ឋកថា

៣៣២- សព្វា ទិសា សប្បុរិសោ បវាយតិ

*សប្បុរសផ្សព្វផ្សាយគុណទៅគ្រប់ទិស*

អង្គ. តិក., ខុ. ធ.

៣៣៣- សាធុ ខោ បណ្ឌិតោ នាម

*ឈ្មោះថាបណ្ឌិតសុទ្ធតែធ្វើប្រយោជន៍ឲ្យសម្រេច*

សំ. ស., ខុ. ជា. ឯក.

៣៣៤- សាធុ សម្ពហុលា ញាតី

ញាតិច្រើនគ្នាធ្វើប្រយោជន៍ឲ្យសម្រេចបាន

ខុ. ជា. ឯក.

៣៣៥- សុវិជានោ ភវំ ហោតិ

អ្នកចំរើន គឺជាគេងាយដឹង

ខុ. សុ.

៣៣៦- សុវិជានោ បរាភវោ

អ្នកវិនាសក៏គឺជាគេងាយដឹងដែរ

ខុ. សុ.

៣៣៧- សុស្សូសា សេដ្ឋា ភរិយានំ

បណ្ដាភរិយាទាំងឡាយ ភរិយាដែលស្ដាប់បង្គាប់ប្រសើរបំផុត

សំ. ស.

៣៣៨- ហិរីនិសេធោ បុរិសោ កោចិ លោកស្មិំ វិជ្ជតិ

បុរសអ្នកកំចាត់អកុសលដោយសេចក្ដីខ្មាស មានតិចគ្នាក្នុងលោក

សំ. ស., ខុ. ធ.

៣៣៩- ហាបេតិ អត្ថំ ទុម្មេធោ

អ្នកឥតប្រាជ្ញា តែងបំផ្លាញប្រយោជន៍

ខុ. ជា. ឯក.

៣៤០ - ទុក្ខំ ករោតិ ទុម្មេធោ

*មនុស្សឥតប្រាជ្ញា តែងធ្វើនូវការប្រទូស្ត*

ខុ. ជា. ទសក.

---

## ១៧ - បុញ្ញវគ្គ

*"ពួកធម៌និយាយអំពីបុណ្យ"*

៣៤១- បុញ្ញំ ចោរេហិ ទូហរំ

*បុណ្យគឺចោរទាំងឡាយ លួចយកមិនបាន*

សំ. ស.

៣៤២- បុញ្ញំ សុខំ ជីវិតសង្ខយម្ហិ

*បុណ្យជាសុខ ក្នុងកាលផុតអស់ជីវិត*

ខុ. ធ.

៣៤៣- បុញ្ញានិ ករិយាថ សុខាវហានិ

*គួរធ្វើនូវបុណ្យទាំងឡាយ ដែលនាំសេចក្តីសុខមកឲ្យ*

សំ. ស., អង្គ. តិក.

៣៤៤- បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ បាណិនំ

*បុណ្យរមែងជាទីពឹង របស់សត្វទាំងឡាយក្នុងលោកខាងមុខ*

សំ. ស., អង្គ. បញ្ចក., ខុ. ជា. ទសក.

៣៤៥- សុខោ បុញ្ញស្ស ឧច្ចយោ

*ការសន្សំបុណ្យ នាំមកនូវសេចក្ដីសុខ*

ខុ. ធ.

---

## ១៨- មច្ចុវគ្គ

*" ពួកធម៌និយាយអំពីសេចក្ដីស្លាប់ "*

៣៤៦- អឌ្ឍា ចេវ ទលិទ្ទា ច សព្វេ មច្ចុបរាយណា

*មនុស្សទាំងអស់ ទាំងអ្នកស្តុកស្តម្ភ ទាំងអ្នកទ័លក្រ*

*សុទ្ធតែមានសេចក្ដីស្លាប់នៅខាងមុខ*

ទី. មហា., ខុ. ជា. ឯក.

៣៤៧- អប្បញ្ចិទំ ជីវិតមាហុ ធីរា

*អ្នកប្រាជ្ញទាំងឡាយ ពោលថាជីវិតនេះតិចណាស់*

ម. ម., ខុ. សុ., ខុ. ថេរ.

៣៤៨- ជរូបនីតស្ស ន សន្តិ តាណា

កាលសត្វត្រូវជរានាំចូលទៅជិតហើយ ទីពឹង

ទាំងឡាយមិនមានឡើយ

សំ. ស., អង្គ. តិក., ខុ. ជា. វិស.

៣៤៩- ន ហាបិ វិត្តេន ជរំ វិហន្តិ

បុគ្គលកំចាត់នូវជរា ដោយទ្រព្យពុំបានឡើយ

ម. ម., ខុ. ថេរ.

៣៥០- ន ទីឃមាយុំ លភតេ ធនេន

មនុស្សមិនបានអាយុវែង ព្រោះទ្រព្យទេ

ម. ម., ខុ. ថេរ.

៣៥១- ន មិយ្យមានំ ធនមន្វេតិ កិញ្ចិ

ទ្រព្យបន្តិចបន្តួចនឹងទៅតាមមនុស្សស្លាប់មិនបានទេ

ម. ម., ខុ. ថេរ.

៣៥២- ន មិយ្យមានស្ស ភវន្តិ តាណា

កាលសត្វស្លាប់ ទីពឹងទាំងឡាយមិនមានទេ

ម. ម., ខុ. ថេរ.

៣៥៣_ ន ហិ នោ សង្គរន្តេន មហាសេនេន មច្ចុនា

*ការតទល់នឹងមច្ចុរាជ ដែលមានសេនាច្រើននោះពុំបានឡើយ*

ម. ឧ., ខុ. ជា. មហា.

៣៥៤_ សព្វំ ភេទបរិយន្តំ ឯវំ មច្ចាន ជីវិតំ

*ជីវិតរបស់សត្វទាំងឡាយ ដូចភាជន៍ដីគ្រប់បែប*

*មានការបែកធ្លាយជាទីបំផុត*

ទី. មហា., ខុ. សុ., ខុ. មហា.

៣៥៥_ សព្វេ វ និក្ខិបិស្សន្តិ ភូតា លោកេ សមុស្សយំ

*ពួកសត្វទាំងអស់ នឹងដាក់ចុះនូវកាយទុកក្នុងលោក*

ទី. មហា., សំ. ស.

---

## ១៩_ មិត្តវគ្គ

*“ ពួកធម៌និយាយអំពីមិត្រ ”*

៣៥៦_ អត្ថម្ហិ ជាតម្ហិ សុខា សហាយា

*កាលបើសេចក្តីត្រូវការកើតឡើង សម្លាញ់ទាំងឡាយ ជាអ្នកនាំយក*

*សុខមកឲ្យ*

ខុ. ធ.

៣៥៧_ នត្ថិ ពាលេ សហាយតា

*សហាយភាពគុណ មិនមានក្នុងបុគ្គលពាលទេ*

វិ. មហា., ម. ខុ., ខុ. ធ.

៣៥៨_ នោ ចេ លភេថ និបកំ សហាយំ

ឯកោ ចរេ ន ច បាបានិ កយិរា

*បើបុគ្គលមិនបាននូវសំឡាញ់មានប្រាជ្ញាចាស់ក្លាទេ គប្បីត្រាច់ទៅ*

*តែម្នាក់ឯង តែថាកុំគប្បីធ្វើនូវបាបទាំងឡាយឡើយ*

វិ. មហា., ម. ខុ., ខុ. ធ.

៣៥៩_ បាបមិត្តោ បាបសខោ បាបអាចារគោចរោ

*បុគ្គលមានមិត្រអាក្រក់ មានសំឡាញ់អាក្រក់ រមែងមានមារយាទ*

*និងគោចរអាក្រក់ដែរ*

ទី. មហា.

៣៦០_ ភរិយា បរមា សខា

*ភរិយាជាសំឡាញ់ដ៏ស្និទ្ធ*

សំ. ស.

៣៦១_ មាតា មិត្តំ សកេ ឃរេ

*មាតាជាមិត្រក្នុងផ្ទះរបស់ខ្លួន*

សំ. ស.

៣៦២- សត្ថោ បវសតោ មិត្តំ

*ពួកឈ្មួញជាមិត្ររបស់អ្នកដើរផ្លូវឆ្ងាយ*

សំ. ស.

៣៦៣- សចេ លភេថ និបកំ សហាយំ

ចរេយ្យ តេនត្តមនោ សតីមា

*បើបុគ្គលបាននូវសំឡាញ់មានប្រាជ្ញាចាស់ក្លា គប្បីពេញចិត្តមាន ស្មារតីត្រាច់ទៅជាមួយសំឡាញ់នោះចុះ*

វិ. មហា. ម. ១., ខុ. ធ.

៣៦៤- សព្វត្ថ បូជិតោ ហោតិ

យោ មិត្តានំ ន ទុព្ភតិ

*អ្នកណាមិនប្រទូស្តចំពោះមិត្រទាំងឡាយ អ្នកនោះរមែងមានគេបូជាក្នុងទីទាំងពួង*

ខុ. ជា. ឆក.

៣៦៥- សព្វេ អមិត្តេ តរតិ យោ មិត្តានំ ន ទុព្ភតិ

*អ្នកណាមិនប្រទូស្តចំពោះមិត្រទាំងឡាយ អ្នកនោះរមែងឆ្លងផុតនូវសត្រូវទាំងពួង*

ខុ. ជា. ឆក.

៣៦៦- សហាយោ អត្ថជាតស្ស ហោតិ មិត្តំ បុនប្បុនំ

*សំឡាញ់ជាមិត្របស់អ្នកមានកិច្ចធុរៈកើតឡើងរឿយៗ*

សំ. ស.

៣៦៧- មិត្តទុព្ភោ ហិ បាបកោ

*អ្នកប្រទូស្តមិត្រ ជាមនុស្សអាក្រក់*

ខុ. ជា. ទសក.

---

## ២០- យាចនាវគ្គ

*"ពួកជនមិននិយាយអំពីសេចក្ដីសូម"*

៣៦៨- ទេស្សោ ច ហោតិ អតិយាចនាយ

*មនុស្សដែលគេស្អប់ ព្រោះតែការសូមហួសប្រមាណ*

វិ. មហាវិភង្គ, ខុ. ជា. តិក.

៣៦៩- ន តំ យាចេ យស្ស បិយំ ជិគីសេ

*បុគ្គលមិនគួរសូមរបស់ជាទីស្រឡាញ់ ដែលគេលំបាកឲ្យឡើយ*

វិ. មហាវិភង្គ, ខុ. ជា. តិក.

៣៧០- ន វេ យាចន្តិ សប្បញ្ញា

*ពួកអ្នកមានបញ្ញា មិនសូមសោះឡើយ*

ខុ. ជា. សត្តក.

៣៧១- យាចំ អទទមប្បិយោ

*បុគ្គលកាលគេសូម មិនឲ្យរបស់ដែលគេសូម រមែងមិនជាទីស្រឡាញ់*

*(របស់អ្នកសូម)*

វិ. មហាវគ្គ, ខុ. ជា. សត្តក.

៣៧២- យាចកោ អប្បិយោ ហោតិ

*អ្នកសូម រមែងមិនជាទីស្រឡាញ់ (របស់អ្នកឲ្យ)*

វិ. មហាវិភង្គ, ខុ. ជា. សត្តក.

---

## ២១- រាជវគ្គ

“ពួកធម៌និយាយអំពីព្រះរាជា”

៣៧៣- កុទ្ធំ អប្បដិកុជ្ឈន្តោ រាជា រដ្ឋស្ស បូជិតោ

*ព្រះរាជាទ្រង់មិនក្រោធតបទៅគេអ្នកក្រោធ រាស្ត្រតែងបូជា*

ខុ. ជា. ចតុក្ក.

៣៧៤- ខត្តិយោ សេដ្ឋោ ជនេតស្មឹ យេ គោត្តប្បដិសារិនោ

*ព្រះមហាក្សត្រិយ៍ប្រសើរបំផុត ជាងពួកជន ដែលប្រកាន់គោត្រ*

ទី. បាដិ., ម. ម., សំ. ស., សំ. និ.

៣៧៥- រាជា មុខំ មនុស្សានំ

*ព្រះរាជាជាប្រធានរបស់មនុស្សទាំងឡាយ*

វិ. មហា., ម. ម., ខុ. សុ.

៣៧៦- រាជា រដ្ឋស្ស បញ្ញាណំ

*ព្រះរាជាជាគ្រឿងប្រាកដរបស់រដ្ឋ*

សំ. ស.

៣៧៧- សន្នទ្ធោ ខត្តិយោ តបតិ

*ព្រះមហាក្សត្រិយ៍មានគ្រឿងក្រោះទ្រង់ហើយ រមែងរុងរឿង*

សំ. និ., ខុ. ធ.

៣៧៨- សព្វំ រដ្ឋំ សុខំ ហោតិ រាជា ចេ ហោតិ ធម្មិកោ

*បើព្រះរាជាទ្រង់ជាអ្នកប្រកបដោយធម៌ ក្រុងទាំងមូលតែងជាសុខ*

អង្គ. ចតុក្ក., ខុ. ជា. ចតុក្ក.

---

## ២២- វាចាវគ្គ

"ពួកធម៌និយាយអំពីវាចា"

៣៧៩- អភូតវាទី និរយំ ឧបេតិ

*មនុស្សនិយាយមិនពិត រមែងចូលទៅនរក*

ខុ. ធ.

៣៨០- ទុជ្ជិស្ស ធិរុសា ភិហា

មនុស្សក្រោធមានពាក្យអាក្រក់

ខុ.ជា.ទសក.

៣៨១- តមេវ វាចំ ភាសេយ្យ យាយត្តានំ ន តាបយេ

បុគ្គលគួរនិយាយតែពាក្យ ដែលមិនញុំាងខ្លួនឲ្យក្ដៅក្រហាយ

សំ.ស.,ខុ.សុ.

៣៨២- ន ហិ មុញ្ចេយ្យ បាបិកំ

បុគ្គលមិនគួរបញ្ចេញពាក្យ អាក្រក់ឡើយ

ខុ.ជា.ឯក.

៣៨៣- នាមនុញ្ញំ កុទាចនំ

ក្នុងកាលណាៗក៏ដោយ មិនគួរនិយាយពាក្យមិនជាទីគាប់ចិត្តឡើយ

ខុ.ជា.ឯក.

៣៨៤- មនុញ្ញមេវ ភាសេយ្យ

បុគ្គលគួរនិយាយតែពាក្យ ដែលជាទីគាប់ចិត្ត

ខុ.ជា.ឯក.

៣៨៥- មុត្តា តបតិ បាបិកំ

បុគ្គលបញ្ចេញពាក្យអាក្រក់ រមែងក្ដៅក្រហាយ

ខុ.ជា ឯក.

៣៨៦- មោក្ខោ កល្យាណិយា សាធុ

ការបញ្ចេញវាចាល្អ ញុំាងប្រយោជន៍ឲ្យសម្រេច

ខុ.ជា.ឯក.

៣៨៧- សំវោហារេន សោចេយ្យំ វេទិតព្វំ

ភាពនៃបុគ្គលស្អាត ត្រូវជ្រាបដោយសំនួនវាចា

ខុ. ឧ.

៣៨៨- សណ្ហំ គិរំ អត្ថវតិំ បមុញ្ចេ

បុគ្គលគួរបញ្ចេញវាចាពីរោះ ដែលមានប្រយោជន៍

ខុ.ជា.តេរស.

៣៨៩- វាចំ បមុញ្ចេ កុសលំ នាតិវេលំ

បុគ្គលមិនគួរថ្លែងវាចាល្អ ឲ្យហួសវេលាឡើយ

ខុ.ជា.ទុក.,ខុ.សុ.,ខុ.មហា.

៣៩០- វាចំ មុញ្ចេយ្យ កល្យាណិំ

បុគ្គលគួរថ្លែងវាចាល្អ

សំ.ស.

៣៩១- ហទយស្ស សទិសី វាចា

វាចាប្រហែលគ្នានឹងដួងចិត្ត

ខុ.ជា.ចតុក្ក.

## ២៣ – វីរិយវគ្គ

" ពួកធម៌និយាយអំពីព្យាយាម "

៣៩២ – អកិលាសុ វិន្ទេ ហទយស្ស សន្តឹ

បុគ្គលមិនខ្ជិលច្រអូស គប្បីបានសេចក្តីស្ងប់ចិត្ត

ខុ. ជា. ឯក.

៣៩៣ – អជ្ជេវ កិច្ចមាតប្បំ

សេចក្តីខំប្រឹង បុគ្គលគួរធ្វើក្នុងថ្ងៃនេះឯង

ម. ឧ., ខុ. ជា. មហា.

៣៩៤ – អបិ បញ្ញា ករុតេ យោគំ កិច្ចេ អាភិសុ សីទតិ

កាលបើបុគ្គលធ្វើសេចក្តីព្យាយាម ក្នុងកិច្ចជាខាងក្រោយនឹង លិចចុះក្នុងវិបត្តិ ( ពុំខាន )

ខុ. ជា. វីស.

៣៩៥ – អនិព្វិន្ទិយការិស្ស សម្មទត្ថោ វិបច្ចតិ

ប្រយោជន៍ដែលសម្រេចដោយប្រពៃដល់អ្នកធ្វើដោយមិនមាន សេចក្តីនឿយណាយ

ខុ. ជា. ចត្តាឡីស.

៣៩៦ – ករេយ្យ យោគំ ធុរមប្បមត្តោ

អ្នកមិនប្រមាទ គួរធ្វើសេចក្តីព្យាយាម ឲ្យទៀងទាត់

ខុ. ជា. ទុក.

៣៩៧– កាលាគតញ្ច ន ហាបេតិ អត្ថំ

*អ្នកមានព្យាយាម រមែងមិនលះប្រយោជន៍ដែលមកដល់តាមកាល*

ខុ. ជា. ឆក្ក

៣៩៨ – ន និព្វិន្ទិយការិស្ស សម្មទត្ថោ វិបច្ចតិ

*ប្រយោជន៍រមែងមិនសម្រេចដោយប្រពៃ ដល់អ្នកធ្វើដោយ*

*មានសេចក្ដីនឿយណាយ*

ខុ. ជា. ចត្តាឡីស.

៣៩៩ – បដិរូបការី ធុរវា ឧដ្ឋាតា វិន្ទតេ ធនំ

*មនុស្សមានធុរៈ ព្យាយាមធ្វើការងារឲ្យហ្មត់ចត់រមែងរកទ្រព្យបាន*

សំ. ស., ខុ. សុ.

៤០០ – យហិំ យហិំ យត្ថ លភេថ អត្ថំ

តហិំ តហិំ តត្ថ បរក្កមេយ្យ

*បុគ្គលគប្បីបានប្រយោជន៍ក្នុងទីណា ដោយប្រការណា ៗ*

*គួរប្រឹងប្រែងក្នុងទីនោះ ដោយប្រការនោះ ៗ*

អង្គ. បញ្ចក., ខុ. ជា. បញ្ចក.

៤០១ – វាយមេថេវ បុរិសោ យាវ អត្ថស្ស និប្ផទា

*កូនប្រុសគប្បីព្យាយាម ទាល់តែសម្រេចប្រយោជន៍*

សំ.ស.

៤០២- ភិយេន ទុក្ខមេច្ចតិ

បុគ្គលតទ្ទឹងទុក្ខបាន ព្រោះសេចក្ដីព្យាយាម

ខុ. សុ.

៤០៣- ជិយ្យតិ ហិយ្យតិ ពោសោ

បរេតិ បរិហាយតិ

បុរស ( គិត ) ថា ចាំស្អែកសិន គ៏វិនាស

( គិត ) ថា ចាំថ្ងៃមុខសិន គ៏វិនាសដែរ

ខុ. ជា. សៃ.

---

## ២៤- វេរវគ្គ

"ពួកជមិនិយាយអំពីពៀរ"

៤០៤- យេ វេរំ ឧបនយ្ហន្តិ វេរំ តេសំ ន សម្មតិ

ជនទាំងឡាយណាចងពៀរ, ពៀររបស់ជនទាំងឡាយនោះមិន

ស្ងប់រម្ងាប់ឡើយ

ម. ឧ., ខុ. ធ., ខុ. ជា. បញ្ចក.

៤០៥- យេ វេរំ នូបនយ្ហន្តិ វេរំ តេសូបសម្មតិ

ជនទាំងឡាយណាមិនចងពៀរ, ពៀររបស់ជនទាំងឡាយនោះ

រមែងស្ងប់រម្ងាប់

ម. ឧ., ខុ. ធ., ខុ. ជា. បញ្ចក.

៤០៦- អវេរេន ច សម្មតិ

ពៀរទាំងឡាយរមែងស្ងប់រម្ងាប់ ដោយមិនមានពៀរ

វិ. មហា., ម. ឧ., ខុ. ធ., ខុ. ជា. បញ្ចក.

៤០៧- ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ

ក្នុងកាលណា ៗ ក៏ដោយ ពៀរទាំងឡាយក្នុងលោកនេះ ស្ងប់រម្ងាប់ដោយពៀរមិនបានឡើយ

វិ. មហា., ម. ឧ., ខុ. ធ., ខុ. ជា. បញ្ចក.

---

## ២៥ - សច្ចវគ្គ

"ពួកធម៌និយាយអំពីសច្ចៈ"

៤០៨- សច្ចំ ហវេ សាធុតរំ រសានំ

ពាក្យសច្ចហ្នឹងឯង ជារសឆ្ងាញ់ជាងរសទាំងឡាយ

សំ. ស., ខុ. សុ.

៤០៩- សច្ចំ វេ អមតា វាចា

ពាក្យសច្ចហ្នឹងឯង ជាវាចាមិនស្លាប់

សំ. ស., ខុ. ថេ.

៤១០- សច្ចេន កិត្តឹ បប្បោតិ

*គេបានកេរ្តិ៍ឈ្មោះ ដោយពាក្យសត្យ*

សំ. ស., ខុ. សុ.

៤១១- សច្ចេ អត្ថេ ច ធម្មេ ច អាហុ សន្តោ បតិដ្ឋិតា

*សប្បុរសទាំងឡាយ បានតាំងនៅក្នុងពាក្យសត្យ ដែលជាអត្ថនិងធម៌*

សំ. ស., ខុ. សុ., ខុ. ថេរ.

៤១២- សច្ចមនុរក្ខេយ្យ

*គប្បីរក្សារឿយៗ នូវពាក្យសត្យ*

ម. ឧ.

---

## ២៦- សតិវគ្គ

*"ពួកពចន៍និយាយអំពីស្មារតី"*

៤១៣- សតិ លោកស្មិ ជាគរោ

*សតិជាគ្រឿងភ្ញាក់រឭកក្នុងលោក*

សំ. ស.

៤១៤- សតីមតោ សទា ភទ្ទំ

*អ្នកមានស្មារតី មានសេចក្ដីចំរើនសព្វកាល*

សំ. ស.

៤១៥- សតិមា សុខមេធតិ

អ្នកមានស្មារតី រមែងដល់សេចក្ដីសុខ

សំ. ស.

៤១៦- សតិមតោ សុវេ សេយ្យោ

អ្នកមានស្មារតី ជាមនុស្សប្រសើររាល់ថ្ងៃ

សំ. ស.

---

## ២៧- សទ្ធាវគ្គ

"ពួកធម៌និយាយអំពីសទ្ធា"

៤១៧- សទ្ធា ពន្ធតិ បាថេយ្យំ

សទ្ធា រមែងចងនូវស្បៀង (គឺកុសល)

សំ. ស.

៤១៨- សទ្ធា សាធុ បតិដ្ឋិតា

សទ្ធាតាំងមាំហើយ ញុំាងប្រយោជន៍ឲ្យសម្រេចបាន

សំ. ស.

៤១៩- សុខា សទ្ធា បតិដ្ឋិតា

សទ្ធាតាំងមាំហើយ នាំសុខមកឲ្យ

ខុ. ធ.

៤២០ - សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ

*សទ្ធាជាទ្រព្យដ៏ប្រសើរ របស់បុរស*

សំ. ស., ខុ. សុ.

៤២១ - សទ្ធា ទុតិយា បុរិសស្ស ហោតិ

*សទ្ធាជាសំឡាញ់ទីពីររបស់បុរស*

សំ. ស.

---

## ២៨- សន្តុដ្ឋិវគ្គ

"ពួកធម៌និយាយអំពីសន្តោស"

៤២២ - សន្តុដ្ឋី បរមំ ធនំ

*សេចក្តីសន្តោសជាទ្រព្យដ៏ក្រៃលែង*

ខុ. ធ.

៤២៣ - តុដ្ឋី សុខា យា ឥតរីតរេន

*សេចក្តីសន្តោសតាមមានតាមបាន នាំសុខមកឲ្យ*

ខុ. ធ.

៤២៤ - សុខោ វិវេកោ តុដ្ឋស្ស សុតធម្មស្ស បស្សតោ

*សេចក្តីស្ងាត់របស់អ្នកសន្តោស មានធម៌ប្រាកដការឃើញ នាំសុខមកឲ្យ*

វិ. មហា., ខុ. ឧ.

៤២៥ - យំ លទ្ធំ តេន តុដ្ឋព្វំ

បានរបស់ណា គប្បីត្រេកអរដោយរបស់នោះ

ខុ. ជា. ឯក.

៤២៦ - សលាភំ នាតិមញ្ញេយ្យ

មិនគួរមើលងាយលាភរបស់ខ្លួន

ខុ. ធ.

## ១៩ - សមណវគ្គ

“ពួកធម៌និយាយអំពីសមណៈ”

៤២៧ - សមណីធ អរណា លោកេ

ពួកសមណៈក្នុងសាសនានេះ មិនមែនជាសឹកសត្រូវក្នុងលោកទេ

សំ. ស.

៤២៨ - ន ហិ បព្វជិតោ បរូបឃាតី

សមណោ ហោតិ បរំ វិហេឋយន្តោ

បព្វជិតសម្លាប់អ្នកដទៃ បៀតបៀនអ្នកដទៃ មិនមែនជាសមណៈឡើយ

ទី. មហា., ខុ. ធ.

៤២៩ - អសញ្ញតោ បព្វជិតោ ន សាធុ

បព្វជិតអ្នកមិនសង្រួម ពុំប្រពៃឡើយ

ខុ. ជា. វីស.

៤៣០ – អបេតោ ទមសច្ចេន ន សោ កាសាវមរហតិ

*(អ្នកណា) ប្រាសចាកទមៈនិងសច្ចៈ អ្នកនោះមិនគួរស្លៀកដណ្តប់*

*សំពត់កាសាវៈឡើយ*

ខុ. ធ., ខុ. ជា. ទុក, ខុ. ថេរ.

៤៣១ – ឧបេតោ ទមសច្ចេន ស វេ កាសាវមរហតិ

*(អ្នកណា) ប្រកបដោយទមៈនិងសច្ចៈ អ្នកនោះឯងទើបគួរស្លៀកដណ្តប់*

*សំពត់កាសាវៈបាន*

ខុ. ធ., ខុ. ជា. ទុក., ខុ. ថេរ.

៤៣២ – សុភាសិតទ្ធជា ឥសយោ

*ឥសីទាំងឡាយ មានសុភាសិតជាទង់ជ័យ*

សំ. និ., អង្គ. ចតុក្ក., ខុ. ជា. អសីតិ.

៤៣៣ – សមណោ អស្ស សុស្សមណោ

*សមណៈ គប្បីជាសមណៈល្អ*

វិ. មហាវគ្គ

---

## ៣៤ - សាមគ្គីវគ្គ

"ពួកធម៌និយាយអំពីសាមគ្គី"

៤៤៣ - សុខា សង្ឃស្ស សាមគ្គី

សេចក្ដីព្រមព្រៀងរបស់ពួក នាំឲ្យកើតសុខ

ខុ. ធ, ខុ. ឥតិ., អង្គ. ទសក.

៤៣៥ - សមគ្គានំ តបោ សុខោ

សេចក្ដីព្រមព្រៀងរបស់អ្នកព្រមព្រៀងគ្នា នាំឲ្យកើតសុខ

ខុ. ធ.

---

## ៣១- សីលវគ្គ

" ពួកធម៌និយាយអំពីសីល "

៤៣៦ - សីលំ យាវ ជរា សាធុ

សីលញ៉ាំងប្រយោជន៍ឲ្យសម្រេចដរាបដល់ជរា

សំ. ស.

៤៣៧ - សុខំ យាវ ជរា សីលំ

សីលនាំសុខមកឲ្យដរាបដល់ជរា

ខុ. ធ.

៤៣៨- សីលំ កិរេវ កល្យាណំ

*លោកថាសីលនុ៎ះឯងជាធម៌ល្អ*

ខុ. ជា. ឯក.

៤៣៩- សីលំ លោកេ អនុត្តរំ

*សីលជាគុណជាតក្រៃលែងក្នុងលោក*

ខុ. ជា. ឯក.

៤៤០- សំវាសេន សីលំ វេទិតព្វំ

*សីលលោកគប្បីដឹងបាន ព្រោះការនៅរួមគ្នា*

ខុ. ឧ.

៤៤១- សាធុ សព្វត្ថ សំវរោ

*សេចក្ដីសង្រួមក្នុងទីទាំងពួងជាការល្អ*

សំ. ស., ខុ. ធ.

៤៤២- សញ្ញមតោ វេរំ ន ចីយតិ

*កាលបុគ្គលមានសេចក្ដីសង្រួម ពៀររមែងមិនកើនឡើង*

ទី. មហា., ខុ. ឧ.

៤៤៣- សីលំ រក្ខេយ្យ មេធាវី

*អ្នកប្រាជ្ញគប្បីរក្សាសីល*

ខុ. ឥតិ.

---

## ៣២-សុខវគ្គ

"ពួកធម៌និយាយអំពីសុខ"

៤៤៤- សព្វស្ស ទុក្ខស្ស សុខំ បហានំ

ការលះទុក្ខទាំងពួងបាន ជាសុខ

ខុ. ធ.

៤៤៥- អព្យាបជ្ឈំ សុខំ លោកេ

ការមិនព្យាបាទ ជាសុខក្នុងលោក

វិ. មហា., ខុ. ឧ.

៤៤៦- តេសំ វូបសមោ សុខោ

ការរម្ងាប់នូវសង្ខារទាំងឡាយនោះ នាំមកនូវសេចក្ដីសុខ

សំ. ស., ខុ. ជា. ឯក.

៤៤៧- នត្ថិ សន្តិបរំ សុខំ

សេចក្ដីសុខដទៃក្រៅពីសេចក្ដីស្ងប់មិនមាន

ខុ. ធ.

៤៤៨- និព្វានំ បរមំ សុខំ

និព្វានជាសុខយ៉ាងក្រៃលែង

ម. ម., ខុ. ធ.

៤៤៩- សុខោ ពុទ្ធានមុប្បាទោ

ការកើតឡើងនៃលោកអ្នកដឹងទាំងឡាយ នាំសុខមកឲ្យ

ខុ. ធ.

៤៥០- សុខា សទ្ធម្មទេសនា

ការសំដែងនូវព្រះសទ្ធម្ម នាំសុខមកឲ្យ

ខុ. ធ.

៤៥១- អទស្សនេន ពាលានំ និច្ចមេវ សុខី សិយា

បុគ្គលគប្បីមានសេចក្ដីសុខជានិច្ចនិរន្តរ៍ ក៏ព្រោះការមិនជួប នូវបុគ្គល

ពាលទាំងឡាយ

ខុ. ធ.

៤៥២- ន ហិ អនត្ថកុសលេន អត្ថចរិយា សុខាវហា

ការប្រព្រឹត្តប្រយោជន៍ជាមួយនឹងបុគ្គលមិនឈ្លាសក្នុងប្រយោជន៍

មិននាំសុខមកឲ្យឡើយ

ខុ. ជា. ឯក.

## ៣៣- សេវនាវគ្គ

" ពួកធម៌និយាយអំពីការសេពគប់ "

៤៥៣- វិស្សាសា ភយមន្វេតិ

ភ័យរមែងដល់បាន ព្រោះសេចក្តីស្និទ្ធ

ខុ. ជា. ឯក.

៤៥៤- អតិចិរំ និវាសេន បិយោ ភវតិ អប្បិយោ

មនុស្សជាទីស្រឡាញ់ ត្រឡប់មិនជាទីស្រឡាញ់វិញ

ព្រោះការនៅរួមគ្នាយូរពេក

ខុ. ជា. តេរស

៤៥៥. ឯករត្តំ ទិរត្តំ វា ទុក្ខំ វសតិ វេរិសុ

(បុគ្គល) នៅក្នុងពួកមនុស្សមានពៀរ អស់មួយយប់ពីរយប់

ក៏ជាទុក្ខ

ខុ. ជា. ឯក.

៤៥៦- ទុក្ខោ ពាលេហិ សំវាសោ អមិត្តេនេវ សព្វទា

ការនៅរួមជាមួយនឹងពួកពាល នាំឲ្យមានទុក្ខគ្រប់កាល

ដូចជាការនៅរួមជាមួយនឹងសត្រូវ

ខុ. ធ.

៤៥៧- ធីរោ ច សុខសំវាសោ ញាតីនំវ សមាគមោ

ការនៅរួមជាមួយនឹងអ្នកប្រាជ្ញនាំឲ្យបានសុខ ដូចជាសមាគមជាមួយនឹងពួកញាតិ

ខុ. ធ.

៤៥៨- សុខោ ហវេ សប្បុរិសេន សង្គមោ

សមាគមជាមួយនឹងសប្បុរស នាំសុខមកឲ្យដោយពិត

ខុ. ជា. ទុក.

៤៥៩- និហីយតិ បុរិសោ និហីនសេវី

បុរសគប់មនុស្សថោកទាប រមែងថោកទាបដែរ

អង្គ.តិក.

៤៦០- ទុក្ខោ ពាលេហិ សង្គមោ

សមាគមនឹងមនុស្សពាលទាំងឡាយ នាំឲ្យមានទុក្ខ

ខុ. ជា.នវក.

៤៦១ ន សង្គមោ បាបជនេន សេយ្យោ

សមាគមជាមួយនឹងជនអាក្រក់ មិនល្អឡើយ

ខុ. ជា. ទុក.

៤៦២- ន បាបជនសំសេវី អច្ចន្តំ សុខមេធតិ

អ្នកមិនគប់រកជនអាក្រក់ តែងដល់នូវសេចក្តីសុខ

ដោយចំណែកមួយ

ខុ. ជា. សត្តក.

៤៦៣- ពាលសង្គតចារី ហិ ទីឃមទ្ធាន សោចតិ

អ្នកប្រព្រឹត្តសមាគមជាមួយនឹងមនុស្សពាល រមែងសៅសោក

អស់កាលយូរ

ខុ. ធ.

៤៦៤- យត្ថ វេរី និវិសតិ ន វសេ តត្ថ បណ្ឌិតោ

មនុស្សមានពៀរនៅក្នុងទីណា បណ្ឌិតមិនគួរនៅក្នុងទី

នោះឡើយ

ខុ. ជា. ឆក្ក.

៤៦៥- សង្កេបេវ អមិត្តស្មិំ

គួររង្កៀស ចំពោះសត្រូវ

ខុ. ជា. ទុក.

៤៦៦- មិត្តស្មិម្បិ ន វិស្សសេ

សូម្បីចំពោះមិត្ត ក៏មិនគួរទុកចិត្តដែរ

ខុ. ជា. ទុក.

៤៦៧ - ន វិស្សសេ អវិស្សត្ថេ

បុគ្គលមិនគួរទុកចិត្តមនុស្ស ដែលមិនស្និទ្ធស្នាលឡើយ

ខុ.ជា.ឯក.

៤៦៨ - វិស្សត្ថេបិ ន វិស្សសេ

សូម្បីមនុស្សស្និទ្ធស្នាល ក៏មិនគួរទុកចិត្តដែរ

ខុ. ជា. ឯក.

៤៦៩ - នាស្មសេ កតបាបម្ហិ

មិនគួរទុកចិត្តមនុស្សធ្វើបាបឡើយ

ខុ. ជា. ទសក.

៤៧០ - នាស្មសេ អលិកវាទិនេ

មិនគួរទុកចិត្តមនុស្សនិយាយមិនពិតឡើយ

ខុ. ជា. ទសក.

៤៧១ - នាស្មសេ អត្តត្ថបញ្ញម្ហិ

មិនគួរទុកចិត្តមនុស្សឃើញតែប្រយោជន៍ផ្ទាល់ខ្លួនឡើយ

ខុ. ជា. ទសក.

៤៧២ - អតិសន្តេបិ នាស្មសេ

មិនគួរទុកចិត្តមនុស្ស ដែលក្លែងធ្វើស្ងប់ស្ងៀមឡើយ

ខុ. ជា. ទសក.

៤៧៣ – អបេតចិត្តេន ន សម្ភជេយ្យ

*មិនគួរគប់នឹងមនុស្សដែលចំលក់ចិត្តឡើយ*

ខុ. ជា. ទសក.

៤៧៤ – ន សន្ថវំ កាបុរិសេន កយិរា

*មិនគួរធ្វើសេចក្ដីស្និទ្ធស្នាលជាមួយនឹងបុរសអាក្រក់ឡើយ*

ខុ. ជា. ទុក.

៤៧៥ – មាស្សុ ពាលេន សង្គច្ឆិ អមិត្តេនេវ សព្វទា

*កុំសមាគមជាមួយនឹងមនុស្សពាល ដែលទុកដូចជាសត្រូវគ្រប់កាល*

ខុ. ជា. នវក.

មានលក់ដុំ និង លក់រាយ

សៀវភៅធម៌គ្រប់មុខគ្រប់ប្រភេទ នៅ "បណ្ណាគារត្រៃរតន៍"

#136E0 វិថីខេមរភូមិន្ទ

ទូរស័ព្ទលេខ: 012 706 581

097 905 00 55

សូមនិមន្ត និង អញ្ជើញដោយមេត្រីភាព ។